ការត្រៀមខ្លួនសម្រាប់
ជីវិតអាពាហ៍ពិពាហ៍
នៅក្នុងព្រះយេស៊ូវគ្រីស្ទ

PREPARING FOR MARRIAGE IN JESUS CHRIST

Scott Sward

Foreward by Ro Tep

ការត្រៀមខ្លួនសម្រាប់ជីវិតអាពាហ៍ពិពាហ៍នៅក្នុងព្រះយេស៊ូវគ្រីស្ទ

មាតិការ

អារម្ភកថា 1-2

សេចក្ដីណែនាំ 3-4

មេរៀនទី១៖ ការភ្ជាប់ពាក្យ 5-8

មេរៀនទី២៖ អាពាហ៍ពិពាហ៍បែបគ្រីស្ទបរិស័ទ 9-13

មេរៀនទី៣៖ សេចក្ដីស្រឡាញ់ពិតប្រាកដ 14-17

មេរៀនទី៤៖ ពីរនាក់ក្លាយជាសាច់ឈាមតែមួយ 18-21

មេរៀនទី៥៖ ការដោះស្រាយទំនាស់ 23-25

មេរៀនទី៦៖ ដួងចិត្តតែមួយ និងសាច់ឈាមតែមួយ (ការរួមដំណេក) 26-28

ឧបសម្ព័ន្ធ៖

«តើខ្ញុំគួររៀបការជាមួយមនុស្សនេះទេ?» 30-31

សំណួរពិភាក្សាជាមួយដៃគូ 32-33

តើព្រះគម្ពីរចែងអ្វីខ្លះអំពីការលែងលះ? 34

ការពន្យល់បន្ថែមអំពី អេភេសូរ ៥:២២-២៤ 35

តារាងរៀបចំកញ្ចប់ថវិកាប្រចាំគ្រួសារ 36

អារម្ភកថា

ការជ្រើសរើសគូរស្រករ គឺជាការជ្រើសរើសដ៏ធំមួយ សម្រាប់មនុស្សគ្រប់ៗគ្នា មិនថាប្រុស ឬស្រី។ ទោះបីគ្រប់គ្នាជាគ្រីស្ទបរិស័ទដូចគ្នាក៏ដោយ ក៏យើងម្នាក់ៗត្រូវមានការប្រុងប្រយ័ត្នក្នុងការសម្រេចចិត្ត ការជ្រើសរើសបុរសនោះ ឬនារីនោះដោយសួរថា *តើគាត់ពិតជាស័ក្តិសមជាមួយនឹងអ្វីដែលព្រះពិតជាបានរៀបចំដែរឬទេ?* មនុស្សគ្រប់គ្នាត្រូវតែមានការគិតពិរចារណាវែងឆ្ងាយក្នុងជ្រើសរើសគូរស្រករដែលខ្លួនពេញចិត្ត ហើយអ្វីដែលពិសេសនោះគឺការជ្រើសរើសគូរស្រករដែលស្របតាមបំណងព្រះហឫទ័យព្រះ ដែលទ្រង់រៀបចំសម្រាប់យើងម្នាក់ៗយ៉ាងពិតប្រាកដ។ ការខកចិត្ត និងការហួសពេលកើតឡើងនៅពេលដែលនារី ឬបុរសណាម្នាក់មិនជ្រើសរើសគិតវែងឆ្ងាយ ហើយមើលស្រាលអំពីអ្វីដែលព្រះណែនាំចេញពីព្រះបន្ទូលរបស់ទ្រង់។ មានគ្រីស្ទានច្រើននាក់ដែលបរាជ័យក្នុងជីវិតអាពាហ៍ពិពាហ៍របស់ពួកគេ ហើយការនេះបានជះឥទ្ធិពលយ៉ាងអាក្រក់ចំពោះដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ និងធ្វើឲ្យព្រះនាមទ្រង់មានការអាប់ឱន ដោយសារការសម្រេចចិត្តដោយមិនបានគិតវែងឆ្ងាយ និងបដិសេធការណែនាំចេញពីព្រះបន្ទូលព្រះ។ មានក្រុមគ្រួសារដែលមិនមែនជាក្រុមគ្រួសារគ្រីស្ទបរិស័ទនៅក្នុងលោកីយ៍មួយចំនួន ពួកគេមានការគិតវែងឆ្ងាយទាក់ទងនឹងលក្ខណៈនារី ឬបុរសបែបណាដែលអាចរស់នៅជាមួយគ្នាបានបន្ទាប់ពីរៀបការជាមួយគ្នា។ ហើយពួកគេក៏រស់នៅជាមួយគ្នាដោយមានសុភមង្គលដោយផ្អែកទៅលើការត្រិះរិះពិចារណារបស់ប្រាជ្ញារបស់លោកីយ៍ និងទ្រព្យសម្បត្តិរបស់ពួកគេ ប៉ុន្តែអ្វីដែលខុសគ្នាគឺថា គ្រួសាររបស់ពួកគេរស់នៅជាមួយគ្នាគឺមិនបានថ្វាយសិរីល្អទៅកាន់ព្រះ ហើយក៏មិនបានឆ្លុះបញ្ចាំងពីដំណឹងល្អ ប៉ុន្តែឆ្លុះបញ្ចាំងពីកេរ្តិ៍ឈ្មោះខ្លួនក្នុងលោកីយ៍របស់ពួកគេតែប៉ុណ្ណោះ។

ការណែនាំ និងការគាំទ្រពីទស្សនៈរបស់លោកីយ៍នៅក្នុងយុគ្គសម័យថ្មីនេះ ហាក់បីដូចជា ធ្វើឲ្យគ្រីស្ទានជាច្រើន ដូចជាមិនចាប់អារម្មណ៍ ហើយអើពើអំពីអ្វីដែលព្រះបន្ទូលបានចែង និងបានណែនាំ។ ហើយការនេះធ្វើឲ្យពួកគេមិនបានគិតវែងឆ្ងាយនោះទេគឺពួកគេគិតថា ការជ្រើសរើសគូរស្រករគឺមិនពិបាក ហើយមានភាពងាយស្រួលជាងមុនៗ ដោយគ្រាន់តែនិយាយថា ស្រឡាញ់ ឬមិនស្រឡាញ់ភ្លាមៗតែប៉ុណ្ណោះ។ ការជ្រើសរើសរៀបការជាមួយអ្នកណាម្នាក់គឺជាការសម្រេចចិត្តមួយដ៏ធំ សម្រាប់បុរសនិងនារី។ ដូចដែលមានប្រយោគមួយពោលថា *ធ្វើស្រែខុសមួយឆ្នាំ ត្រូវមួយឆ្នាំ តែបើរៀបការវិញខុសម្តង គឺខុសមួយជីវិត។* ដូចនេះវាជាការសំខាន់ណាស់ក្នុងការចំណាយពេលវេលាឲ្យគ្រប់គ្រាន់ដើម្បីស្វែងយល់អំពីបំណងព្រះហឫទ័យរបស់ព្រះ មុនពេលដែលយើងសម្រេចចិត្តរៀបការជាមួយបុរសនោះ ឬនារីនោះ។ បំណងព្រះហឫទ័យរបស់ព្រះ គឺចង់ឲ្យគ្រីស្ទបរិស័ទគ្រប់ៗគ្នាបានគិតវែងឆ្ងាយក្នុងការជ្រើសរើសគូរស្រករ ទ្រង់មិនចង់ឃើញដៃគូរទាំងសងខាងមានការបែកបាក់ ប្រេះឆា លែងលះគ្នា

បន្ទាប់ពីរៀបការនោះទេ ហើយទ្រង់ក៏សព្វព្រះហឫទ័យឲ្យគ្រប់គ្នាសង្កេតមើលអំពីអ្វីដែលទ្រង់បានណែនាំចេញពីព្រះបន្ទូលទ្រង់ជាចាំបាច់ផងដែរ។ វាការចាំបាច់បំផុតក្នុងដែលយើងជាគ្រីស្ទបរិស័ទត្រូវស្វែងយល់អំពីអ្វីដែលទ្រង់បានណែនាំដល់យើងជាអាទិភាពបំផុត។ ការសម្រេចចិត្តដោយខ្លួនឯងដោយមិនបានគិតវែងឆ្ងាយគឺជាការសម្រេចដ៏ងាយស្រួលបំផុត ហើយការសម្រេចចិត្តនោះគឺមិនបានថ្វាយសិរីល្អទៅកាន់ទ្រង់ហើយក៏បញ្ជាក់ថា លោកអ្នកមិនមានភាពពេញវ័យខាងឯព្រលឹងវិញ្ញាណទាល់តែសោះ។ ព្រះបន្ទូលព្រះមិនត្រឹមតែណែនាំលោកអ្នកឲ្យស្គាល់នារី ឬបុរសបែបណាដែលលោកអ្នកត្រូវជ្រើសរើសនោះទេ ប៉ុន្តែក៏បានណែនាំលោកអ្នកពីបុរស និងនារីដែលលោកអ្នកត្រូវជៀសចេញផងដែរ។

សៀវភៅមួយនេះគឺជាជំនួយដល់លោកអ្នកឲ្យមានការគិតវែងឆ្ងាយ ហើយនិងជួយលោកអ្នកឲ្យស្វែងរកឃើញពីបំណងព្រះហឫទ័យព្រះយ៉ាងពិតប្រាកដ ដើម្បីឲ្យលោកអ្នកឆ្លុះបញ្ចាំងឃើញថា *តើបុរសឬនារីដែលលោកអ្នកកំពុងជ្រើសរើសនោះពិតជាស័ក្តិសមជាមួយលោកអ្នកក្នុងការបន្តដំណើរជីវិតជាមួយគ្នា ឬការថ្វាយសិរីល្អទៅកាន់ព្រះយេស៊ូវគ្រីស្ទដែរឬទេ?*

សេចក្ដីណែនាំ

សៀវភៅនេះត្រូវបានចងក្រងឡើង ដើម្បីជាជំនួយដល់គ្រីស្ទបរិស័ទ ដែលបានភ្ជាប់ពាក្យរួច អាចរៀបចំខ្លួនបានល្អ មុននឹងឈានចូលជីវិតអាពាហ៍ពិពាហ៍។ សៀវភៅនេះ ចែកចេញជាមេរៀនខ្លីៗចំនួនប្រាំមួយ គឺៈ

១. ការភ្ជាប់ពាក្យ
២. អាពាហ៍ពិពាហ៍បែបគ្រីស្ទបរិស័ទ
៣. សេចក្ដីស្រឡាញ់ពិតប្រាកដ
៤. ពីរនាក់ក្លាយជាសាច់ឈាមតែមួយ
៥. ការដោះស្រាយទំនាស់
៦. ដួងចិត្តតែមួយ និងសាច់ឈាមតែមួយ (ការរួមដំណេក)

វាជាការល្អបំផុត ប្រសិនបើគូដណ្ដឹង ទាំងសងខាង អាចសិក្សាមេរៀនទាំងនេះ ជាមួយនឹងអ្នកប្រឹក្សា ជាប្ដី ប្រពន្ធ ដែលអាចជួយណែនាំពួកគេ ពីជីវិតអាពាហ៍ពិពាហ៍(ឧទាហរណ៍ គ្រូគង្វាល និងភរិយារបស់គាត់ ជាដើម)។

មេរៀននីមួយៗ មានបីផ្នែកៈ

១. អានមេរៀនៈ គូដណ្ដឹងទាំងសងខាង ត្រូវអានមេរៀន មុនពេលជួបជាមួយអ្នកប្រឹក្សា។

២. ជួបជាមួយអ្នកប្រឹក្សាៈ គូដណ្ដឹងទាំងពីរនាក់ មកជួបជាមួយអ្នកប្រឹក្សា ដើម្បីពិភាក្សាពីខ្លឹមសារមេរៀន។

៣. កិច្ចការផ្ទះៈ គូដណ្ដឹងទាំងសងខាង ធ្វើកិច្ចការផ្ទះ ហើយអានមេរៀនបន្ទាប់។

គូដណ្ដឹងទាំងសងខាង គួរតែជួបជាមួយអ្នកប្រឹក្សាទាំងអស់គ្នា ដើម្បីពិភាក្សាពីមេរៀននិមួយៗ។ ក៏ប៉ុន្តែ ដោយសារមេរៀនទី៦ ទាក់ទងនឹងប្រធានបទអំពីការរួមភេទ យើងស្នើឲ្យភាគីខាងប្រុសជួបជាមួយអ្នកប្រឹក្សាជាបុរសដូចគ្នា ហើយភាគីខាងស្រីជួបជាមួយអ្នកប្រឹក្សាជាស្ត្រីដូចគ្នា។

ដូចដែលយើងបានរៀបរាប់ខាងលើ វាជាការល្អបំផុតសម្រាប់គូដណ្ដឹងទាំងពីរនាក់ ក្នុងការពិភាក្សាខ្លឹមសារមេរៀនទាំងនេះ ជាមួយអ្នកប្រឹក្សា ជាប្ដីប្រពន្ធ។ ប្រសិនបើគូដណ្ដឹងទាំងពីរនាក់ ពិបាករកអ្នកប្រឹក្សាជាគូប្ដីប្រពន្ធ អ្នកទាំងពីរនោះ អាចជួបជាមួយអ្នកប្រឹក្សាតែម្នាក់ក៏បាន។ ទោះជាយ៉ាងណាក៏ដោយ សម្រាប់មេរៀនទី៦ យើងនៅតែណែនាំខាងបុរសឲ្យពិភាក្សាមេរៀនជាមួយអ្នកប្រឹក្សាជាបុរស ហើយខាងកូនស្រីជាមួយអ្នកប្រឹក្សាជាស្ត្រី។

តួនាទីសំខាន់របស់អ្នកប្រឹក្សា មិនមែនដើម្បីបង្រៀនមេរៀនទេ។ ផ្ទុយទៅវិញ ការងាររបស់ពួកគេគឺជាការសួរសំណួរ លើកទឹកចិត្ត និងចែករំលែកបទពិសោធន៍របស់ពួកគេផ្ទាល់។ អ្នកប្រឹក្សាគួរតែជាមនុស្សដែលស្រឡាញ់ព្រះយេស៊ូវ ស្រឡាញ់ប្ដី ឬប្រពន្ធខ្លួន ហើយចេះណែនាំ និងលើកទឹកចិត្តអ្នកដទៃ ដោយក្ដីស្រឡាញ់។

លើសពីនេះទៅទៀត ពេលចាប់ផ្តើមកិច្ចសន្ទនាលើកដំបូង អ្នកប្រឹក្សាគួរតែបញ្ជាក់ឲ្យច្បាស់ថា ពួកគេនឹងរក្សាការសម្ងាត់ទាំងអស់ដែលគូដណ្តឹងទាំងពីរនាក់ ចែកចាយជាមួយពួកគេ។ ចំណុចនេះពិតជាសំខាន់ណាស់ ព្រោះវាជួយកសាងនូវទំនុកចិត្ត។

ប្រសិនបើអ្នកមានសំណួរទាក់ទងនឹងមេរៀនទាំងនេះ សូមទាក់ទងអ្នកនិពន្ធតាមរយៈ៖

sward.scott78@gmail.com

មេរៀនទី១៖ ការភ្ជាប់ពាក្យ

«បើមនុស្សពីរនាក់មិនព្រមចិត្តគ្នា នោះតើនឹងដើរជាមួយគ្នាបានឬ?» (អេម៉ុស ៣:៣)

ក. ពេលវេលានៃការភ្ជាប់ពាក្យ

សូមអបអរសាទរ អ្នកទាំងពីរបានភ្ជាប់ពាក្យហើយ! នេះគឺជាពេលវេលាដ៏ពិសេសមួយនៅក្នុងជីវិតរបស់អ្នក។ វាជាពេលវេលាដ៏សំខាន់ ដោយសារហេតុផលបីយ៉ាង។

ទីមួយ នេះគឺជាពេលវេលានៃការរៀបចំ។ ដោយសារអ្នកបានភ្ជាប់ពាក្យរួចរាល់ហើយ អ្នកក៏ប្រហែលជាកំពុងចាប់ផ្ដើមរវល់ជាមួយនឹងការរៀបចំសម្រាប់ថ្ងៃរៀបការរបស់អ្នកជាក់ជាពុំខាន។ ច្បាស់ណាស់ថា ការរៀបចំនេះពិតជារឿងដ៏សំខាន់។ ប៉ុន្តែតាមពិតទៅ ការរៀបចំសម្រាប់ជីវិតអាពាហ៍ពិពាហ៍ គឺសំខាន់ជាងការរៀបចំសម្រាប់ថ្ងៃរៀបអាពាហ៍ពិពាហ៍ទៅទៀត។ ការរៀបអាពាហ៍ពិពាហ៍មានរយៈពេលតែមួយថ្ងៃប៉ុណ្ណោះ ចំណែកឯជីវិតអាពាហ៍ពិពាហ៍វិញ គឺមានរយៈពេលពេញមួយជីវិត។

ទីពីរ នេះជាពេលវេលាដើម្បីស្គាល់គ្នាឲ្យកាន់តែច្បាស់។ មុនពេលអ្នករៀបការ វាសំខាន់ណាស់សម្រាប់អ្នក និងគូដណ្ដឹងអ្នក ក្នុងការនិយាយគ្នាដោយបើកចំហរ។ មុនរៀបការ បើអ្នកទាំងពីរនិយាយគ្នាកាន់តែច្រើន ក្រោយរៀបការរួច ជីវិតអាពាហ៍ពិពាហ៍របស់អ្នកនឹងកាន់តែរលូនបានច្រើនតាមនោះដែរ។ ដូច្នេះហើយ ត្រូវចាប់និយាយគ្នាអំពីរឿងធំៗ និងរឿងតូចតាចពីឥឡូវនេះទៅ។ ត្រូវនិយាយអំពីអតីតកាលរបស់អ្នក ទាំងរឿងរីករាយ និងរឿងទុក្ខលំបាក ហើយត្រូវនិយាយអំពីអនាគតផងដែរ។ តើអ្នកមានសេចក្ដីសង្ឃឹមបែបណាខ្លះ? តើអ្នកភ័យខ្លាចអ្វីខ្លះ? តើអ្នកមានគោលដៅអ្វីខ្លះ? មិនត្រូវលាក់បាំងអ្វីមួយជាមួយនឹងគូដណ្ដឹងអ្នកឡើយ។

ទីបី នេះជាពេលវេលាដើម្បីបញ្ជាក់ពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ចំពោះជីវិតអ្នក។ ពេលស្វាមី ភរិយារៀបការ ព្រះជាម្ចាស់ចងពួកគេជាមួយគ្នាអស់មួយជីវិត។ ប៉ុន្តែការភ្ជាប់ពាក្យវិញ មិនមានអត្ថន័យដូចការរៀបការនោះទេ។ ប្រសិនបើគូដណ្ដឹងដែលបានភ្ជាប់ពាក្យរួច បែរជាបែកបាក់គ្នាវិញ វាអាចជារឿងសោកសៅខ្លាំងណាស់ ប៉ុន្តែវាមិនមែនជាអំពើបាបឡើយ (១ កូរិនថូស ៧:៣៧)។ ប៉ុន្តែបន្ទាប់ពីរៀបការរួច ការបែកបាក់គ្នា មិនមែនចាជម្រើសនោះឡើយ។ ហេតុនេះហើយ វាជារឿងសំខាន់សម្រាប់អ្នក និងគូដណ្ដឹងរបស់អ្នក ក្នុងការប្រើប្រាស់ពេលវេលានេះដើម្បីបញ្ជាក់ថា៖ តើវាពិតជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់អ្នកទាំងពីរ ដើម្បីរៀបអាពាហ៍ពិពាហ៍មែនឬទេ?

ខ. ការរៀបចំខាងវិញ្ញាណ

ប្រសិនបើអ្នកចង់ឲ្យព្រះជាម្ចាស់ប្រទានពរដល់ជីវិតរបស់អ្នកទាំងពីរ អ្នកត្រូវតែដាក់ព្រះយេស៊ូវជាអាទិភាព ក្នុងទំនាក់ទំនងរបស់អ្នក។ នេះមានន័យថា អ្នកត្រូវចំណាយពេលអធិស្ឋានជាមួយគ្នា អានព្រះគម្ពីរជាមួយគ្នា បម្រើក្រុមជំនុំជាមួយគ្នា និងលើកទឹកចិត្តគ្នាទៅវិញមកឲ្យនៅតែទុកចិត្ត និងស្ដាប់បង្គាប់ព្រះជាម្ចាស់ជានិច្ច។

វាក៏មានន័យថា អ្នកត្រូវតែរង់ចាំរហូតដល់ថ្ងៃអ្នករៀបការ ទើបអាចរួមដំណេកជាមួយគ្នាផងដែរ។ ដូចដែលអ្នកនឹងរៀននៅក្នុងមេរៀនទី៦ ការរួមភេទគឺជាព្រះពរដ៏ពិសេស ដែលព្រះជាម្ចាស់បំរុងទុក សម្រាប់តែគូស្វាមីភរិយាប៉ុណ្ណោះ។

ប្រសិនបើអ្នកបានរួមដំណេកជាមួយគ្នា មុនពេលរៀបការនោះ អ្នកគួរតែសារភាពអំពើបាបរបស់អ្នកចំពោះព្រះជាម្ចាស់ (១ យ៉ូហាន ១:៩)។ បន្ថែមពីនេះ អ្នកនិងគូដណ្ដឹងរបស់អ្នកគួរតែប្ដេជ្ញាចិត្តស្ដាប់បង្គាប់ព្រះជាម្ចាស់ ដោយការមិនរួមភេទម្ដងទៀតរហូតដល់ក្រោយពេលអ្នករៀបការរួច (១ កូរិនថូស ៦:១៨-២០)។

គ. បញ្ជាក់អំពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់

ការជ្រើសរើសរៀបការជាមួយអ្នកណាម្នាក់ គឺជាការសម្រេចចិត្តដ៏ធំ។ ដូចដែលមានឃ្លាមួយពោលថា៖ «ធ្វើស្រែខុសមួយឆ្នាំ ត្រូវមួយឆ្នាំ តែបើរៀបការវិញ ខុសម្ដង គឺខុសមួយជីវិត»។ ដូចនេះហើយ វាសំខាន់ណាស់ក្នុងការចំណាយពេលឲ្យបានគ្រប់គ្រាន់ ដើម្បីស្វែងយល់ពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ មុនពេលអ្នករៀបការ។ កុំគ្រាន់តែធ្វើតាមអារម្មណ៍របស់អ្នកនោះឡើយ។ ត្រូវស្ដាប់តាមព្រះសូរសៀងរបស់ព្រះជាម្ចាស់វិញ។

មានវិធីបីយ៉ាងសំខាន់ៗ ដើម្បីស្វែងយល់ពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ គឺតាមរយៈព្រះគម្ពីរ ការអធិស្ឋាន និងមនុស្សផ្សេងទៀត។

1. **ព្រះគម្ពីរ៖** ព្រះគម្ពីរហាមមិនឲ្យគ្រីស្ដបរិស័ទ រៀបការនឹងអ្នកដែលមិនមែនជាគ្រីស្ទបរិស័ទ (២ កូរិនថូស ៦:១៤-១៨)។ នេះមានន័យថា ប្រសិនបើគូដណ្ដឹងអ្នក មិនមានទំនាក់ទំនងផ្ទាល់ខ្លួនជាមួយព្រះយេស៊ូវទេ អ្នកមិនត្រូវរៀបការជាមួយគាត់ ជាដាច់ខាត។ វាមិនមែនជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ទាល់តែសោះ ដែលអ្នកជឿព្រះយេស៊ូវ រៀបការជាមួយនឹងអ្នកដែលមិនជឿព្រះយេស៊ូវ។

2. **ការអធិស្ឋាន៖** ដើម្បីជ្រើសរើសមនុស្សត្រឹមត្រូវរៀបការ អ្នកត្រូវការប្រាជ្ញាជាច្រើន។ ចូរសុំប្រាជ្ញាពីព្រះជាម្ចាស់ (យ៉ាកុប ១:៥)។ សុំឲ្យទ្រង់ដឹកនាំអ្នក និងគូដណ្ដឹងរបស់អ្នកតាមបំណងព្រះហឫទ័យរបស់ព្រះអង្គ ហើយប្រសិនបើក្នុងហេតុផលណាមួយ វាមិនមែនជាព្រះហឫទ័យរបស់ទ្រង់ ឲ្យអ្នកទាំងពីររៀបការនឹងគ្នានោះទេ ចូរសុំឲ្យទ្រង់បញ្ជាក់ពីការណ៍នោះឲ្យបានច្បាស់ទៅកាន់អ្នកទាំងពីរ។[1]

3. **មនុស្សផ្សេងទៀត៖** ព្រះជាម្ចាស់ក៏អាចប្រើមនុស្សផ្សេងទៀតដើម្បីជួយយើងឲ្យយល់ពីបំណងព្រះហឫទ័យរបស់ទ្រង់ផងដែរ (សុភាសិត ១៥:២២)។ តើឪពុកម្ដាយរបស់អ្នកគិតយ៉ាងណាចំពោះគូដណ្ដឹងរបស់អ្នក? ចុះគ្រូគង្វាល ឬមិត្តភក្តិគ្រីស្ទានចាស់ទុំឯទៀតវិញ តើពួកគាត់គិតយ៉ាងណាដែរ? តើពួកគាត់គាំទ្រទំនាក់ទំនងរបស់អ្នកទាំងពីរទេ? ចូរសុំឲ្យអ្នកទាំងនោះ ចែករំលែកចិត្តគំនិតរបស់ពួកគាត់ដោយស្មោះត្រង់មកកាន់អ្នក។

---

[1] ដើម្បីជួយអ្នកឲ្យយល់ដឹងពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ សូមឆ្លើយសំណួរទាំងអស់នៅក្នុង «តើខ្ញុំគួររៀបការជាមួយមនុស្សនេះពិតឬទេ?» នៅក្នុងឧបសម្ព័ន្ធ។

បើអ្នកបានរួមដំណេកជាមួយគ្នារួចហើយ វាពិតជាពិបាក ក្នុងការស្តាប់ឮព្រះសូរសៀងរបស់ព្រះជាម្ចាស់ និងពិបាកយល់ច្បាស់ពីបំណងព្រះហឫទ័យរបស់ទ្រង់ណាស់។ ការរួមភេទមុនរៀបការអាចធ្វើឲ្យអ្នករៀបការជាមួយមនុស្សខុស ហើយនាំឲ្យមានការសោកស្តាយអស់មួយជីវិត។ នេះជាហេតុផលមួយទៀតដែលវាសំខាន់ខ្លាំងណាស់ ក្នុងការរង់ចាំរហូតដល់ថ្ងៃអ្នករៀបការ មុនពេលដែលអ្នកទាំងពីររួមដំណេកជាមួយគ្នា។

ឃ. ទម្លាប់សំខាន់៖ ស្តាប់គ្នាទៅវិញទៅមក

គូស្វាមីភរិយាខ្លះរស់នៅជាមួយគ្នាយ៉ាងមានសុភមង្គល រីឯគូស្វាមីភរិយាផ្សេងទៀតគឺឈ្លោះប្រកែកគ្នារហូត។ ហេតុអ្វីបានជាយ៉ាងនេះ? ហេតុផលមួយគឺ គូស្នេហ៍ដែលមានសុភមង្គលទាំងនោះបានរៀនទម្លាប់សំខាន់មួយចំនួន។

នៅក្នុងមេរៀនទាំងនេះ អ្នកនឹងរៀនអំពីទម្លាប់៦ ដែលចាំបាច់សម្រាប់ជីវិតអាពាហ៍ពិពាហ៍ដ៏ប្រសើរមួយ។ វាជារឿងសំខាន់សម្រាប់អ្នក និងគូដណ្តឹងរបស់អ្នក ដើម្បីចាប់ផ្តើមបង្កើតទម្លាប់ទាំងនេះ មុនពេលអ្នករៀបការ។ នៅពេលដែលអ្នកអនុវត្តទម្លាប់ទាំងនេះកាន់តែច្រើន ទម្លាប់ទាំងនេះក៏នឹងក្លាយទៅជារឿង ដែលកាន់តែងាយស្រួល។

ទម្លាប់សំខាន់ដំបូងដែលអ្នក និងគូដណ្តឹងអ្នកត្រូវរៀន គឺត្រូវចេះស្តាប់គ្នាទៅវិញទៅមក។ គូស្នេហ៍ជាច្រើនឈ្លោះគ្នា ពីព្រោះពួកគេមិនចេះស្តាប់គ្នា។ ព្រះគម្ពីរចែងថា៖ *«ដូច្នេះ បងប្អូនស្ងួនភ្ងាអើយ ចូរឲ្យគ្រប់គ្នាបានឆាប់នឹងស្តាប់ ក្រនឹងនិយាយ ហើយយឺតនឹងខឹងដែរ»* (យ៉ាកុប ១:១៩)។

នេះគឺជាជំនាញស្តាប់ជាមូលដ្ឋានមួយចំនួន៖

1. **ស្តាប់ដោយការយកចិត្តទុកដាក់៖** បិទទូរស័ព្ទ វិទ្យុ និងទូរទស្សន៍។ បើអាច ទៅកន្លែងស្ងាត់។
2. **ភាសាកាយវិការ៖** ងាកទៅរកមុខប្តី ឬប្រពន្ធរបស់អ្នក។ សំឡឹងចំកែវភ្នែកគាត់។ សម្រាកសាច់ដុំមុខ និងដងខ្លួនរបស់អ្នក។
3. **កុំនិយាយបង្អាក់៖** នៅពេលប្តី ឬប្រពន្ធរបស់អ្នកនិយាយ ចូរស្តាប់ដោយអត់ធ្មត់។ ព្យាយាមគ្រប់គ្រងអារម្មណ៍របស់អ្នក។ កុំនិយាយខ្លាំងជាងគាត់ និយាយកាត់គាត់ គ្រវីក្បាល ឬកែតម្រូវគាត់ឡើយ។ រង់ចាំឲ្យគាត់និយាយចប់សិន សឹមអ្នកឆ្លើយតបវិញ។
4. **សួរសំណួរបញ្ជាក់៖** មុនពេលឆ្លើយតបទៅប្តី ឬប្រពន្ធរបស់អ្នក ត្រូវប្រាកដថាអ្នកយល់ពីអ្វីដែលពួកគេបាននិយាយ។ អ្នកអាចសួរសំណួរដូចជា «អូនអន់ចិត្ត ព្រោះ... តើនោះជាការពិតទេ?» «តើបងអាចពន្យល់អូនបានទេថា បងចង់មានន័យយ៉ាងម៉េច ពេលបងនិយាយថា...?

ដើម្បីមានសុភមង្គលក្នុងអាពាហ៍ពិពាហ៍ វាសំខាន់ណាស់ដែលអ្នក និងគូដណ្តឹងអ្នកត្រូវចេះស្តាប់គ្នា។ ពេលណាអ្នកចាប់ផ្តើមអនុវត្តជំនាញស្តាប់ទាំងបួននេះកាន់តែឆាប់ កាន់តែល្អ។

ង. សំណួរពិភាក្សាជាមួយអ្នកប្រឹក្សា

(**សំណួរអំពីប្រវត្តិគូស្នេហ៍**)

1. តើអ្នកមកពីណា?
2. តើអ្នកមានបងប្អូនប៉ុន្មាននាក់?
3. តើឪពុកម្ដាយរបស់អ្នកនៅរស់ទេ? បើពួកគាត់នៅរស់ តើពួកគាត់នៅជុំគ្នាទេ?
4. តើអ្នកនឹងពណ៌នាអំពីគ្រួសាររបស់អ្នកយ៉ាងដូចម្ដេច (កក់ក្ដៅ និងជិតស្និទ្ធ, ឬ សោះអង្គើយ និងមិនអើពើ, ឬ រឹករវ និងតានតឹង)?
5. តើអ្នកទាំងពីរស្គាល់គ្នាយូរប៉ុណ្ណាហើយ?
6. តើអ្នកក្លាយជាគូស្នេហ៍ដំបូងនៅពេលណា?
7. តើអ្វី ដែលទាក់ទាញចិត្តអ្នកឲ្យស្រឡាញ់គូដណ្ដឹងរបស់អ្នក?
8. តើអ្នកទាំងពីរចូលចិត្តធ្វើអ្វីខ្លះ ជាមួយគ្នា?
9. តើអ្នកបានភ្ជាប់ពាក្យយូរប៉ុណ្ណាហើយ?
10. តើអ្នកមានគម្រោងរៀបការនៅពេលណា?

(**សំណួរអំពីមេរៀន**)

11. តើចំណុចអ្វីខ្លះក្នុងមេរៀន ដែលទាក់ទាញចំណាប់អារម្មណ៍អ្នក?
12. តើមានចំណុចអ្វីខ្លះ នៅក្នុងមេរៀននេះ ដែលអ្នកមិនទាន់យល់ទេ?
13. ក្នុងចំណោមជំនាញស្ដាប់ទាំងបួន តើជំនាញមួយណាដែលអ្នកធ្វើបានល្អជាងគេ? ជំនាញណាដែលអ្នកនៅខ្សោយនៅឡើយ?
14. ចាប់ពីថ្ងៃនេះទៅ តើអ្នកសន្យាថាមិនរួមដំណេកជាមួយគ្នារហូតដល់រៀបការដែរឬទេ?
15. តើមានចំណុចអ្វីផ្សេងទៀត ដែលអ្នកចង់សួរ ឬពិភាក្សានៅថ្ងៃនេះ ឬទេ?

ច. កិច្ចការផ្ទះ

1. ប្រសិនបើអ្នកមិនទាន់បានធ្វើវាទេ សូមអាន និងឆ្លើយសំណួរទាំងអស់នៅក្នុង «តើខ្ញុំពិតជាគួររៀបការជាមួយគូដណ្ដឹងរបស់ខ្ញុំមែនទេ?» នៅក្នុងឧបសម្ព័ន្ធ ដោយខ្លួនឯង។
2. សូមជួបជាមួយគូដណ្ដឹងរបស់អ្នក ហើយសួរគ្នាទៅវិញទៅមកនូវសំណួរពិភាក្សាជាមួយដៃគូ ១-៩ នៅក្នុងឧបសម្ព័ន្ធ។
3. នៅពេលអ្នកជួបជាមួយគូដណ្ដឹងរបស់អ្នក សូមអនុវត្តជំនាញស្ដាប់ជាមូលដ្ឋានទាំងបួនដែលបានពិពណ៌នាខាងលើ។
4. សូមអានមេរៀនទី២។

មេរៀនទី២៖ អាពាហ៍ពិពាហ៍បែបគ្រីស្ទបរិស័ទ

«ដោយហេតុនោះបានជាមនុស្សប្រុសនឹងលាចេញពីឪពុកម្ដាយ ទៅនៅជាប់នឹងប្រពន្ធ ហើយអ្នកទាំងពីរនោះនឹងត្រឡប់ជាសាច់តែមួយវិញ សេចក្ដីអាថ៌កំបាំងនេះជ្រៅណាស់ តែខ្ញុំនិយាយខាងឯព្រះគ្រីស្ទនឹងពួកជំនុំវិញ។» (អេភេសូរ ៥:៣១-៣២)

ក. ប្រភេទផ្សេងៗនៃអាពាហ៍ពិពាហ៍

ពីបុរាណកាលរហូតមកដល់បច្ចុប្បន្ននេះ មនុស្សម្នាបានរៀបអាពាហ៍ពិពាហ៍។ ប៉ុន្តែមិនមែនគ្រប់គ្នាសុទ្ធតែមានគំនិតដូចគ្នាអំពីអាពាហ៍ពិពាហ៍នោះទេ។ ជាទូទៅ មនុស្សមានទស្សនៈ៣យ៉ាងខុសៗគ្នាចំពោះប្រធានបទនេះ គឺ អាពាហ៍ពិពាហ៍បែបប្រពៃណី អាពាហ៍ពិពាហ៍បែបសម័យទំនើប និងអាពាហ៍ពិពាហ៍បែបគ្រីស្ទបរិស័ទ។

អាពាហ៍ពិពាហ៍បែបប្រពៃណី	**អាពាហ៍ពិពាហ៍បែបសម័យទំនើប**
គ្រួសារគឺសំខាន់បំផុត	ខ្លួនឯងគឺសំខាន់បំផុត
គោលដៅផ្ដោតលើ៖ • កូនៗ • ការផ្គត់ផ្គង់ក្រុមគ្រួសារ • កិត្តិយសក្រុមគ្រួសារ	គោលដៅផ្ដោតលើ៖ • សុភមង្គល • សេចក្ដីស្រឡាញ់ • ភាពជាគូកននឹងគ្នា
អាពាហ៍ពិពាហ៍ គឺជាកាតព្វកិច្ចគ្រួសារ	អាពាហ៍ពិពាហ៍ គឺជាជម្រើសផ្ទាល់ខ្លួន
អត្រាលែងលះទាប	អត្រាលែងលះខ្ពស់

អាពាហ៍ពិពាហ៍បែបគ្រីស្ទបរិស័ទ មានលក្ខណៈខុសពីអាពាហ៍ពិពាហ៍បែបប្រពៃណី និងអាពាហ៍ពិពាហ៍បែបសម័យទំនើប។ អាពាហ៍ពិពាហ៍បែបគ្រីស្ទបរិស័ទ ប្រសើរជាងអាពាហ៍ពិពាហ៍ពីរប្រភេទទៀត ដោយសារតែវាតាក់តែងឡើងដោយព្រះជាម្ចាស់ផ្ទាល់តែម្ដង។

កាលពីដើមដំបូងឡើយ មនុស្សមិនមែនជាអ្នកបង្កើតឲ្យមានអាពាហ៍ពិពាហ៍នោះទេ គឺជាព្រះជាម្ចាស់ទេតើ ដែលបង្កើតអាពាហ៍ពិពាហ៍ឡើង។ អាពាហ៍ពិពាហ៍បែបគ្រីស្ទបរិស័ទ គឺជាការតាក់តែងដំបូងបំផុតរបស់ព្រះជាម្ចាស់។

ដើម្បីបង្កើតឲ្យមានអាពាហ៍ពិពាហ៍បែបគ្រីស្ទបរិស័ទបាន ជាការចាំបាច់បំផុត ដែលទាំងភាគីប្ដី និងប្រពន្ធ ត្រូវមានទំនាក់ទំនងផ្ទាល់ខ្លួនជាមួយនឹងព្រះយេស៊ូវគ្រីស្ទទាំងពីរនាក់ (២ កូរិនថូស ៦:១៤)។ ការរៀបចំពិធីមង្គលការតាមបែបគ្រីស្ទបរិស័ទតែមួយមុខ នៅមិនទាន់គ្រប់គ្រាន់នៅឡើយទេ។ ប្រសិនបើអ្នកចង់រស់នៅជាមួយគ្នាប្រកបដោយព្រះពរពីព្រះ អ្នកទាំងពីរត្រូវតែតែទទួលយកព្រះគ្រីស្ទ ជាព្រះសង្គ្រោះរបស់អ្នក ព្រមទាំងដើរតាមទ្រង់ ទុកជាម្ចាស់ជីវិតផ្ទាល់ខ្លួន ជារៀងរាល់ថ្ងៃផង។

ខ. អាពាហ៍ពិពាហ៍បែបគ្រីស្ទបរិស័ទ៖ រូបភាពតូចមួយនៃសេចក្តីស្រឡាញ់ដ៏ធំធេងរបស់ព្រះជាម្ចាស់

ព្រះជាម្ចាស់ទ្រង់ស្រឡាញ់អាពាហ៍ពិពាហ៍! ព្រះគម្ពីរចាប់ផ្តើមជាមួយនឹងពិធីមង្គលការរបស់អ័ដាម និងអេវ៉ា (លោកុប្បត្តិ ២) ហើយវាបញ្ចប់ទៅវិញជាមួយនឹងពិធីជប់លៀងនៃអាពាហ៍ពិពាហ៍របស់កូនចៀម (វិវរណៈ ២១)។ មូលហេតុដែលព្រះជាម្ចាស់ស្រឡាញ់អាពាហ៍ពិពាហ៍ គឺដោយសារទំនាក់ទំនងអាពាហ៍ពិពាហ៍ គឺជារូបភាពតូចមួយ ដែលបង្ហាញអំពីទំនាក់ទំនងរបស់ព្រះគ្រីស្ទជាមួយនឹងក្រុមជំនុំ។ ព្រះគម្ពីរចែងថា ព្រះយេស៊ូវគឺជាកូនកំឡោះ ហើយក្រុមជំនុំគឺជាកូនក្រមុំរបស់ទ្រង់។

គោលបំណងដ៏ជ្រាលជ្រៅបំផុតនៃអាពាហ៍ពិពាហ៍ នោះគឺដើម្បីឲ្យទំនាក់ទំនង(អាពាហ៍ពិពាហ៍)របស់អ្នក បង្ហាញនូវសេចក្តីស្រឡាញ់រវាងព្រះគ្រីស្ទ និងរាស្ត្ររបស់ទ្រង់។

ក្នុងអាពាហ៍ពិពាហ៍បែបគ្រីស្ទបរិស័ទ ព្រះជាម្ចាស់គឺជាអាទិភាពសំខាន់បំផុត។ គូស្វាមីភរិយាគ្រីស្ទបរិស័ទលើកតម្កើងព្រះជាម្ចាស់ដោយស្រឡាញ់គ្នាទៅវិញទៅមក តាមរបៀបដែលព្រះយេស៊ូវស្រឡាញ់ពួកគេ។ សំខាន់ជាងនេះទៅទៀត អាពាហ៍ពិពាហ៍មិនមែនផ្តោតទៅលើតែក្រុមគ្រួសារ ឬក៏ផ្តោតតែទៅលើខ្លួនឯងតែប៉ុណ្ណោះទេ។ អាពាហ៍ពិពាហ៍បែបគ្រីស្ទបរិស័ទ គឺផ្តោតទៅលើព្រះជាម្ចាស់ជាចំបង។

ប្រសិនបើអ្នកបានរៀបអាពាហ៍ពិពាហ៍រួចហើយ នេះមានន័យថាព័ន្ធកិច្ចដ៏ធំបំផុតរបស់អ្នកនៅលើផែនដី គឺការស្រឡាញ់ និងបម្រើប្តីឬប្រពន្ធរបស់អ្នក។ នៅពេលដែលគូស្វាមីភរិយាព្យាយាមអស់ពីចិត្ត ក្នុងការថែទាំគ្នាទៅវិញទៅមក ស្តាប់គ្នាទៅវិញទៅមក អត់ឱនឲ្យគ្នាទៅវិញទៅមក និងឲ្យតម្លៃគ្នាទៅវិញទៅមក ពីមួយឆ្នាំទៅមួយឆ្នាំ នោះធ្វើឲ្យទំនាក់ទំនងរបស់ពួកគេក្លាយជារូបភាពដ៏ស្រស់សោភា ដែលឆ្លុះបញ្ចាំងឲ្យមនុស្សបានឃើញអំពីដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ។ គូស្វាមីភរិយាដែលស្រឡាញ់គ្នាទៅវិញទៅមក ដូចដែលព្រះយេស៊ូវគ្រីស្ទស្រឡាញ់ពួកគេ គឺកំពុងចែករំលែកដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទទៅកាន់មនុស្សនៅជុំវិញពួកគេ តាមរយៈជីវិតរបស់ពួកគេផ្ទាល់។

គ. ការចងសម្ព័ន្ធមេត្រី

នៅពេលដែលគូស្វាមីភរិយារៀបការជាមួយគ្នា ពួកគេក្លាយជាសាច់ឈាមតែមួយ (ម៉ាកុស ១០:៧-៨)។ គ្មានអ្វីដែលអាចបំបែកចំណងមេត្រីនេះរវាងពួកគេបានឡើយ លើកលែងតែសេចក្តីស្លាប់តែម៉្យាងប៉ុណ្ណោះ (ហើយអាចជាអំពើផិតក្បត់ផងដែរ[2])។ ព្រះគម្ពីរហៅការចងចំណងមេត្រីប្រភេទនេះថាជា «ការចងសម្ព័ន្ធមេត្រី» (ម៉ាឡាគី ២:១៤)។ ព្រះជាម្ចាស់បានបង្កើតសម្ព័ន្ធមេត្រីអាពាហ៍ពិពាហ៍ ជាសញ្ញាសំគាល់នៃចំណងដែលមិនអាចបំបែកបានរវាងព្រះគ្រីស្ទ និងក្រុមជំនុំរបស់ទ្រង់ (អេភេសូរ ៥:៣១-៣២)។

ក្នុងអាពាហ៍ពិពាហ៍របស់គ្រីស្តបរិស័ទ សម្ព័ន្ធមេត្រីរវាងប្តីប្រពន្ធគឺមានសេរីភាព ស្មោះត្រង់ និងជានិរន្ត៍។

[2] សូមមើល *តើព្រះគម្ពីរនិយាយអ្វីខ្លះអំពីការលែងលះ* នៅក្នុងឧបសម្ព័ន្ធ។

១. **សេរីភាព៖** «ខ្ញុំ (ឈ្មោះ) យកអ្នក (ឈ្មោះ) ធ្វើជាស្វាមី / ភរិយារបស់ខ្ញុំ»។
២. **ស្មោះត្រង់៖** «ខ្ញុំសន្យាថានឹងស្មោះត្រង់នឹងអូន/បង...»
៣. **ជានិរន្តរ៍៖** «...មិនថាពេលសុខសប្បាយ ឬពេលមានទុក្ខវេទនា មិនថាមានជំងឺ ឬសុខភាពល្អ។ ខ្ញុំនឹងស្រឡាញ់ និងផ្តល់កិត្តិយសដល់អូន/បង ពេញមួយជីវិតរបស់ខ្ញុំ»។

ក្នុងចំណងអាពាហ៍ពិពាហ៍ អារម្មណ៍ដែលគូស្វាមីភរិយាមានចំពោះគ្នាទៅវិញទៅមក អាចមានចុះមានឡើង។ ប៉ុន្តែចំណងអាពាហ៍ពិពាហ៍បែបគ្រីស្ទបរិស័ទ មិនមែនអាស្រ័យទៅតាមអារម្មណ៍នោះទេ។ ចំណងអាពាហ៍ពិពាហ៍នេះ គឺអាស្រ័យទៅលើសម្ព័ន្ធមេត្រី ដែលជាការសន្យារបស់ប្តីប្រពន្ធចំពោះព្រះជាម្ចាស់ និងចំពោះគ្នាទៅវិញទៅមក។ ដូច្នេះហើយ នៅពេលដែលយើងត្រៀមលក្ខណៈចូលទៅក្នុងចំណងអាពាហ៍ពិពាហ៍ សំណួរដែលសំខាន់បំផុតដែលយើងត្រូវសួរគូដណ្តឹងរបស់យើងនោះ មិនមែនជាសំណួរថា «តើអូន/បងស្រឡាញ់ខ្ញុំទេ ?» នោះទេ ប៉ុន្តែគឺជាថា «តើអូន/បងនឹងស្រឡាញ់ខ្ញុំនៅគ្រប់កាលៈទេសៈទាំងអស់ ដែរឬទេ ?»។

អាពាហ៍ពិពាហ៍មិនអាស្រ័យលើអារម្មណ៍របស់យើងទេ។ វាអាស្រ័យទៅលើការដែលយើងរក្សាពាក្យសន្យារបស់យើង។ វាអាស្រ័យលើការដែលយើងឲ្យតម្លៃទៅលើការចងសម្ព័ន្ធមេត្រី ដែលយើងបានធ្វើនៅចំពោះព្រះភ័ក្រ្តព្រះជាម្ចាស់។

ក្រោយពីអ្នកបានរៀបការរួចហើយ វាគ្មានប្រយោជន៍អ្វីក្នុងការដែលអ្នកគិតថា អ្នកប្រហែលជាបានរៀបការជាមួយមនុស្សខុសនោះទេ។ ចាប់ពីពេលដែលអ្នកចូលក្នុងចំណងអាពាហ៍ពិពាហ៍រួចមក មិនថាមានរឿងអ្វីកើតឡើងទេ វាគឺជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ក្នុងការដែលអ្នក និងប្តី ឬប្រពន្ធរបស់អ្នក ថែរក្សានូវសម្ព័ន្ធមេត្រីអាពាហ៍ពិពាហ៍ ដែលអ្នកបានចងចំពោះព្រះភ័ក្រ្តទ្រង់ និងសាក្សីផ្សេងទៀត។ នោះហើយជាមូលហេតុដែលវាមានសារៈសំខាន់ខ្លាំងណាស់ ក្នុងការដែលយើងត្រូវដឹងច្បាស់ មុនថ្ងៃអាពាហ៍ពិពាហ៍របស់យើងថា៖ តើវាពិតជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ សម្រាប់ខ្ញុំក្នុងការរៀបការជាមួយបុគ្គលនេះ ឬយ៉ាងណា ?

ឃ. ទម្លាប់សំខាន់៖ ការអធិស្ឋានរួមគ្នា

បើគ្មានជំនួយពីព្រះគ្រីស្ទនោះទេ អាពាហ៍ពិពាហ៍បែបគ្រីស្ទបរិស័ទ មិនគ្រាន់តែពិបាកប៉ុណ្ណោះទេ តែវាគឺមិនអាចទៅរួចតែម្តង។ នោះហើយជាមូលហេតុដែលវាចាំបាច់ណាស់ ដែលអ្នក និងប្តីឬប្រពន្ធរបស់អ្នក មិនត្រឹមតែផ្តល់អាទិភាពដល់ទំនាក់ទំនងផ្ទាល់ខ្លួនរបស់អ្នកជាមួយព្រះយេស៊ូវប៉ុណ្ណោះទេ (តាមរយៈការអធិស្ឋាន ការអានព្រះគម្ពីរ និងការចូលរួមជាមួយក្រុមជំនុំ) វាក៏ចាំបាច់ផងដែរដែលអ្នកទាំងពីរត្រូវចំណាយពេល ដើម្បីអធិស្ឋានជាមួយគ្នា ជារៀងរាល់ថ្ងៃ។

គូស្វាមីភរិយាដែលអធិស្ឋានជាមួយគ្នា នៅជាប់ជាមួយគ្នា។ លើសពីនេះ គូស្វាមីភរិយាគ្រីស្ទបរិស័ទ ដែលអធិស្ឋានជាមួយគ្នាញឹកញាប់ នឹងមានសុភមង្គលជាងគូផ្សេងទៀត។

ឆ្នាំដំបូងនៃអាពាហ៍ពិពាហ៍ គឺជាពេលវេលាដ៏ល្អបំផុតដើម្បីបង្កើតទម្លាប់នៃការអធិស្ឋានជាមួយគ្នា។ អ្នកនិងប្ដីប្រពន្ធរបស់អ្នកគួរជ្រើសរើសពេលវេលាណា ដែលល្អសម្រាប់អ្នកទាំងពីរ (ឧទាហរណ៍ ពេលអ្នកក្រោកពីគេងពេលព្រឹក ឬមុនពេលអ្នកចូលគេងពេលយប់)។ វាមិនសំខាន់ថា អ្នកទាំងពីរត្រូវអធិស្ឋានយូរៗនោះទេ។ អ្វីដែលសំខាន់បំផុតនោះគឺថា អ្នកទាំងពីរតែងតែអធិស្ឋានជាមួយគ្នាប្រចាំថ្ងៃ និងមិនបោះបង់ទម្លាប់នេះចោលទេ។ ព្រះជាម្ចាស់ចង់ប្រទានពរដល់អាពាហ៍ពិពាហ៍របស់អ្នក ហើយទ្រង់ចង់បង្រៀនអ្នកពីរបៀបស្រឡាញ់គ្នាទៅវិញទៅមក ដូចជាព្រះយេស៊ូវស្រឡាញ់ក្រុមជំនុំដែរ។ ដើម្បីទទួលបានព្រះពរទាំងនេះ អ្នកនិងប្ដីប្រពន្ធរបស់អ្នកត្រូវអធិស្ឋានជាមួយគ្នាជារៀងរាល់ថ្ងៃ។

ង. សំណួរពិភាក្សាជាមួយអ្នកប្រឹក្សា

1. តើអ្នកបានធ្វើកិច្ចការផ្ទះហើយ ឬនៅ? តើអ្នកគិតដូចម្តេច អំពីកិច្ចការផ្ទះនោះ?
2. តើចំណុចអ្វីខ្លះក្នុងមេរៀន ដែលទាក់ទាញចំណាប់អារម្មណ៍អ្នក?
3. តើមានចំណុចអ្វីខ្លះ នៅក្នុងមេរៀននេះ ដែលអ្នកមិនទាន់យល់ទេ?
4. តើអាពាហ៍ពិពាហ៍មានន័យយ៉ាងណាចំពោះអ្នក?
5. តើអ្នកគិតថាឃ្លានេះមានន័យយ៉ាងណា៖ «អាពាហ៍ពិពាហ៍មិនអាស្រ័យលើអារម្មណ៍របស់យើងទេ។ វាអាស្រ័យទៅលើការដែលយើងរក្សាពាក្យសន្យារបស់យើង។ វាអាស្រ័យលើការដែលយើងឲ្យតម្លៃទៅលើការចងសម្ព័ន្ធមេត្រី ដែលយើងបានធ្វើនៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់។»?
6. នៅក្នុងមេរៀននេះ មានឃ្លាថា៖ «សំណួរដែលសំខាន់បំផុតដែលយើងត្រូវសួរគូដណ្តឹងរបស់យើងនោះ មិនមែនជាសំណួរថា "តើអូន/បងស្រឡាញ់ខ្ញុំទេ?" នោះទេ ប៉ុន្តែគឺជាថា "តើអូន/បងនឹងស្រឡាញ់ខ្ញុំនៅគ្រប់កាលៈទេសៈទាំងអស់ ដែរឬទេ?"»។ ប្រសិនបើគូដណ្តឹងរបស់អ្នកសួរអ្នកសំណួរនេះមកកាន់អ្នក តើអ្នកនឹងឆ្លើយសំណួរនេះយ៉ាងដូចម្តេច?
7. តើព្រះគម្ពីរចែងយ៉ាងណាអំពីការលែងលះ? ចុះអ្នកវិញ តើអ្នកយល់យ៉ាងណាដែរចំពោះការលែងលះ?
8. សម្រាប់ខ្លួនអ្នកផ្ទាល់ តើអាពាហ៍ពិពាហ៍ដែលល្អ និងមានសុភមង្គលមានលក្ខណៈបែបណាខ្លះ?
9. បន្ទាប់ពីអ្នករៀបការរួច តើវាសំខាន់សម្រាប់អ្នកក្នុងការអធិស្ឋានជាមួយគ្នាជារៀងរាល់ថ្ងៃដែរឬទេ? ហេតុអ្វី?
10. តើមានចំណុចអ្វីផ្សេងទៀត ដែលអ្នកចង់សួរ ឬពិភាក្សានៅថ្ងៃនេះ ឬទេ?

ច. កិច្ចការផ្ទះ

1. សរសេរសំបុត្រទៅគូដណ្តឹងរបស់អ្នកដោយចាប់ផ្តើមដោយពាក្យថា «ក្នុងនាមជាប្តី/ប្រពន្ធរបស់អូន/បង ខ្ញុំសន្យាថានឹង ... » បន្ទាប់មក សូមជូនលិខិតរបស់អ្នកទៅកាន់គូដណ្តឹងរបស់អ្នក។
2. សូមជួបជាមួយគូដណ្តឹងរបស់អ្នក ហើយសួរគ្នាទៅវិញទៅមកនូវសំណួរពិភាក្សាជាមួយដៃគូ ១០-១៨ នៅក្នុងឧបសម្ព័ន្ធ។
3. សូមអធិស្ឋានជាមួយគ្នា យ៉ាងហោចណាស់ម្តងក្នុងមួយសប្តាហ៍។
4. សូមអានមេរៀនទី៣។

មេរៀនទី៣៖ សេចក្តីស្រឡាញ់ដ៏ពិតប្រាកដ

«ស្រឡាញ់ដល់គ្នាទៅវិញទៅមក ដូចជាខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ។» (យ៉ូហាន ១៥:១២)

ក. សេចក្តីស្រឡាញ់ពិតប្រាកដ និងសេចក្តីស្រឡាញ់ក្លែងក្លាយ

ដើម្បីទទួលបានសុភមង្គលក្នុងជីវិតអាពាហ៍ពិពាហ៍ អ្នកត្រូវតែស្គាល់យ៉ាងច្បាស់ថា អ្វីទៅជាសេចក្តីស្រឡាញ់ពិតប្រាកដ និងអ្វីទៅជាសេចក្តីស្រឡាញ់ក្លែងក្លាយ។ ព្រះគម្ពីរពិពណ៌នាសេចក្តីស្រឡាញ់ពិតប្រាកដយ៉ាងដូច្នេះ៖

«ឯសេចក្តីស្រឡាញ់តែងតែអត់ធ្មត់ ហើយក៏សប្បុរស សេចក្តីស្រឡាញ់មិនចេះឈ្នានីស មិនចេះអួតខ្លួន ក៏មិនដែលមានចិត្តធំផង មិនដែលប្រព្រឹត្តបែបមិនគួរសម មិនដែលរកប្រយោជន៍ផ្ទាល់ខ្លួន មិនរហ័សខឹង មិនប្រកាន់ទោស មិនដែលអរសប្បាយចំពោះសេចក្តីទុច្ចរិតឡើយ គឺអរសប្បាយតែនឹងសេចក្តីស្មោះត្រង់វិញ ក៏គ្របបាំងទាំងអស់ ជឿទាំងអស់ សង្ឃឹមទាំងអស់ ហើយទ្រាំទ្រទាំងអស់» (១ កូរិនថូស ១៣:១៤-៨)។

សេចក្តីស្រឡាញ់ពិត មិនសំដៅទៅលើអារម្មណ៍ដែលយើងមាន ឬពាក្យសម្ដីដែលយើងនិយាយតែមាត់នោះទេ។ សេចក្តីស្រឡាញ់ពិតប្រាកដគឺ ស្តែងចេញមកតាមរយៈទង្វើរបស់យើង។ នៅក្នុងចំណងអាពាហ៍ពិពាហ៍ សេចក្តីស្រឡាញ់ពិត គឺជាការប្រព្រឹត្តចំពោះប្តី ឬប្រពន្ធរបស់អ្នក ដូចរបៀបដែលព្រះយេស៊ូវគ្រីស្ទទ្រង់ប្រព្រឹត្តចំពោះអ្នក។

ពេលខ្លះមនុស្សយើងមានការយល់ច្រឡំរវាងសេចក្តីស្រឡាញ់ពិតប្រាកដ និងសេចក្តីស្រឡាញ់ក្លែងក្លាយ។ ប៉ុន្តែសេចក្តីស្រឡាញ់ទាំងពីរប្រភេទនេះ ពិតជាមានលក្ខណៈខុសគ្នាទាំងស្រុង។

ខ

សេចក្តីស្រឡាញ់ក្លែងក្លាយ	**សេចក្តីស្រឡាញ់ពិតប្រាកដ**
ផ្តោតលើអារម្មណ៍	ស្តែងចេញជាសកម្មភាព
ប្រើប្រាស់ដៃគូ	បម្រើដៃគូ
ចង់បំពេញចិត្តខ្លួនឯង	លះបង់ខ្លួនឯង ដើម្បីបំពេញចិត្តដៃគូ
គ្រប់គ្រងដៃគូ	ទុកចិត្តលើដៃគូ
ចង់បានភ្លាម	អត់ធ្មត់

ខ. សត្រូវដ៏ធំបំផុត

ហេតុអ្វីបានជាសេចក្តីស្រឡាញ់នៅក្នុងចំណងអាពាហ៍ពិពាហ៍ ពេលខ្លះក៏ចាប់ផ្តើមស្ងិតស្រពោន និងលែងមានអារម្មណ៍ចំពោះគ្នាតទៅទៀត? មូលហេតុធំបំផុតនោះគឺ ភាពអាត្មានិយម។ ភាពអាត្មានិយម គឺដូចជាមហារីកដែលស៊ីបំផ្លាញចំណងអាពាហ៍ពិពាហ៍។

បន្ទាប់ពីព្រះជាម្ចាស់បានរៀបការឲ្យអ័ដាម និងអេវ៉ា ព្រះគម្ពីរចែងថា៖ *«រីឯអ័ដាម នឹងប្រពន្ធគាត់ក៏នៅជាអាក្រាតទទេ ឥតមានសេចក្ដីអៀនខ្មាសឡើយ»* (លោកុប្បត្តិ ២:២៥)។ ពាក្យទាំងនេះជារូបភាពនៃសេចក្ដីស្រឡាញ់ដ៏ពិតប្រាកដ។

ប៉ុន្តែ គួរឲ្យស្ដាយណាស់ អ័ដាម និងអេវ៉ាមិនបានស្ដាប់បង្គាប់តាមព្រះជាម្ចាស់ឡើយ ហើយអំពើបាបរបស់ពួកគេមិនគ្រាន់តែប៉ះពាល់ដល់ទំនាក់ទំនងរបស់ពួកគេជាមួយព្រះប៉ុណ្ណោះទេ។ វាថែមទាំងប៉ះពាល់ដល់ទំនាក់ទំនងដែលពួកគេមានជាមួយគ្នាទៅវិញទៅមកផងដែរ។ ហេតុនេះហើយបានជាព្រះជាម្ចាស់មានបន្ទូលប្រាប់អេវ៉ាថា៖ *«ចិត្តឯងនឹងប្រាថ្នាខាងឯប្ដី ហើយប្ដីនិងត្រួតត្រាលើឯង»* (លោកុប្បត្តិ ៣:១៦)។

អំណាចបាបតែងអូសទាញប្រពន្ធឲ្យចង់គ្រប់គ្រង ឬកាច់ប្ដីរបស់ខ្លួន ហើយអំណាចបាបក៏អូសទាញប្ដីឲ្យទៅត្រួតត្រា និងប្រើប្រាស់ប្រពន្ធខ្លួនដែរ។ ដោយសារភាពអាត្មានិយម មិនបានបម្រើគ្នាទៅវិញទៅមក ដូចព្រះគ្រីស្ទបម្រើក្រុមជំនុំនោះឡើយ។ ផ្ទុយទៅវិញ ពួកគេប្រកួតប្រជែងគ្នារហូត។

ភាពអាត្មានិយម គឺជាសត្រូវដ៏ធំបំផុតនៃអាពាហ៍ពិពាហ៍របស់អ្នក។ នេះមានន័យថា ជារៀងរាល់ថ្ងៃ អ្នកនិងប្ដីប្រពន្ធរបស់អ្នក ត្រូវតែខិតខំដើម្បីឆ្កាងភាពអាត្មានិយមនៅក្នុងចិត្តរបស់អ្នកផ្ទាល់ (កាឡាទី ៥:២៤)។ បើមិនដូច្នោះទេ ភាពអាត្មានិយមនោះនឹងបំផ្លាញអាពាហ៍ពិពាហ៍របស់អ្នកជាក់ជាមិនខាន។

គ. ព្រះយេស៊ូវ គឺជាប្រភព និងគំរូនៃសេចក្ដីស្រឡាញ់ពិតប្រាកដ

តើអ្នកនិងប្ដីប្រពន្ធរបស់អ្នកអាចយកឈ្នះលើភាពអាត្មានិយម ហើយរៀនស្រឡាញ់គ្នាយ៉ាងពិតប្រាកដបានដោយរបៀបណា? ចម្លើយនោះគឺស្ថិតលើព្រះយេស៊ូវ។

ជាដំបូង អ្នកត្រូវតែបើកចិត្តទទួលសេចក្ដីស្រឡាញ់ពីព្រះយេស៊ូវ។ ព្រះគម្ពីរមានព្រះបន្ទូលថា៖ *«យើងមានចិត្តស្រឡាញ់ ព្រោះព្រះអង្គបានស្រឡាញ់យើងជាមុន»* (១ យ៉ូហាន. ៤:១៩)។ មានន័យថា ដើម្បីមានដួងចិត្តស្រឡាញ់ អ្នកត្រូវតែទទួលសេចក្ដីស្រឡាញ់ពីទ្រង់ជាមុនសិន។ ដើម្បីអត់ទោសឲ្យអ្នកដទៃបាន នោះអ្នកត្រូវតែទទួលការអត់ទោសពីទ្រង់ជាមុនសិន។ ដើម្បីឲ្យអ្នកអាចមានចិត្តលះបង់ដូចជាព្រះយេស៊ូវបាន អ្នកក៏ត្រូវទទួលយកការលះបង់របស់ទ្រង់សម្រាប់អ្នកជាមុនផងដែរ។

ទីពីរ អ្នកត្រូវតែពឹងផ្អែកលើព្រះយេស៊ូវ។ ព្រះយេស៊ូវគឺជាប្រភពនៃសេចក្ដីស្រឡាញ់ដ៏ពិតប្រាកដ។ បើអ្នកពឹងអាងលើព្រះយេស៊ូវ នោះទ្រង់នឹងបំពេញដួងចិត្តអ្នក ដោយសេចក្ដីស្រឡាញ់របស់ទ្រង់ ជារៀងរាល់ថ្ងៃ។ បើគ្មានទ្រង់ទេ មិនយូរមិនឆាប់ សេចក្ដីស្រឡាញ់របស់អ្នកនឹងស្ងួតហួតហែងជាក់ជាមិនខាន។

ដើម្បីឲ្យអ្នកអាចស្រឡាញ់ប្ដី ឬប្រពន្ធរបស់អ្នកយ៉ាងពិតប្រាកដបាន ទីមួយអ្នកត្រូវទទួលសេចក្ដីស្រឡាញ់ពីព្រះយេស៊ូវជាមុនសិន។ រីឯចំណុចសំខាន់ទីពីរគឺ អ្នកត្រូវពឹងផ្អែកនៅលើទ្រង់ ហើយចំណុចទីបី អ្នកត្រូវធ្វើតាមគំរូរបស់ទ្រង់។ សាវ័កប៉ុលបានសរសេរថា៖ *«កុំធ្វើអ្វីដោយចង់ប្រកួតប្រជែងគ្នា ឬដោយអួតបំប៉ោងឡើយ ផ្ទុយទៅវិញ ត្រូវដាក់ខ្លួន ហើយចាត់ទុកអ្នកឯទៀតៗ ថា ប្រសើរជាងខ្លួន។ ក្នុងចំណោមបងប្អូនម្នាក់ៗ កុំគិតតែពី*

ប្រយោជន៍ផ្ទាល់ខ្លួនឡើយ គឺត្រូវគិតដល់ប្រយោជន៍អ្នកដទៃវិញ។ ព្រះគ្រិស្តយេស៊ូមានចិត្តគំនិតយ៉ាងណា បងប្អូនត្រូវមានចិត្តគំនិតយ៉ាងនោះដែរ» (ភីលីព ២:៣- ៥)។

ដើម្បីឲ្យអាពាហ៍ពិពាហ៍ទទួលបានសុភមង្គល ប្ដីប្រពន្ធត្រូវយកគំរូតាមព្រះយេស៊ូវ។ នេះមានន័យថា ស្វាមីមិនត្រូវត្រួតត្រា ឬសោះអង្គើយដាក់ប្រពន្ធខ្លួនឡើយ។ ផ្ទុយទៅវិញ ស្វាមីទាំងឡាយត្រូវតែស្រឡាញ់ ការពារ និងបម្រើភរិយាខ្លួន ដូចដែលព្រះយេស៊ូវស្រឡាញ់ ការពារ និងបម្រើកូនក្រមុំរបស់ទ្រង់ ដែលជាក្រុមជំនុំដែរ (អេភេសូរ ៥:២៥-២៩)។ ចំណែកឯភរិយាវិញ មិនត្រូវព្យាយាមគ្រប់គ្រងប្ដីឡើយ។ ផ្ទុយទៅវិញ ពួកគេត្រូវតែស្រឡាញ់ គោរព និងចុះចូលចំពោះស្វាមីខ្លួន ដូចជាពួកជំនុំស្រឡាញ់ គោរព និងចុះចូលចំពោះព្រះគ្រីស្ទដូច្នោះដែរ (អេភេសូរ ៥:២២-២៤[3])។

ព្រះយេស៊ូវជាប្រភព និងគំរូនៃសេចក្ដីស្រឡាញ់ដ៏ពិតប្រាកដ។ ដើម្បីឲ្យអ្នកអាចស្រឡាញ់ប្ដីប្រពន្ធរបស់អ្នកបាន អ្នកត្រូវតែពឹងអាងលើព្រះយេស៊ូវគ្រីស្ទ និងទទួលយកទ្រង់ជាគំរូ។

ឃ. ទម្លាប់សំខាន់ៗ៖ សកម្មភាពតូចៗដែលបង្ហាញពីសេចក្ដីស្រឡាញ់

អ្នកម្ដាយធីរេសា (Mother Theresa) ដែលជាបេសកជនកាតូលិកម្នាក់ និងបានបម្រើជនក្រីក្រនៅប្រទេសឥណ្ឌា ធ្លាប់បាននិយាយថា៖ «មិនមែនយើងទាំងអស់គ្នាសុទ្ធតែអាចធ្វើកិច្ចការធំអស្ចារ្យបាននោះទេ ប៉ុន្តែយើងទាំងអស់គ្នាអាចធ្វើកិច្ចការតូចតាចដែលបង្កប់ដោយក្ដីស្រឡាញ់យ៉ាងធំអស្ចារ្យបាន។» អាពាហ៍ពិពាហ៍ក៏មានលក្ខណៈដូច្នេះដែរ។

គូស្នេហ៍ដែលមានសុភមង្គល មិនរង់ចាំដល់ឱកាសពិសេសៗ ដូចជាថ្ងៃខួបកំណើត ឬថ្ងៃខួបអាពាហ៍ពិពាហ៍ ទើបបង្ហាញពីក្ដីស្រឡាញ់ចំពោះគ្នាទៅវិញទៅមកឡើយ។ ផ្ទុយទៅវិញ ពួកគេបង្ហាញសេចក្ដីស្រឡាញ់របស់ខ្លួនជារៀងរាល់ថ្ងៃ តាមរយៈទង្វើតូចៗដែលមានលក្ខណៈសាមញ្ញធម្មតា។ ពួកគេតែងតែជួយគ្នាទៅវិញទៅមក លើកទឹកចិត្តគ្នាទៅវិញទៅមក ចំណាយពេលជាមួយគ្នា និងបង្ហាញពីក្ដីស្រលាញ់ចំពោះគ្នា (ដោយពាក្យផ្អែមល្ហែម ឱបថើប អំណោយជាកាដូបន្តិចបន្តួច ឬការជួយសម្រាលបន្ទុកគ្នា ជាដើម)។

អាគារធំៗត្រូវបានកសាងឡើងដោយប្រើដុំឥដ្ឋតូចៗ។ ដូចគ្នាដែរ អាពាហ៍ពិពាហ៍ដ៏មានសុភមង្គល ត្រូវបានបង្កើតឡើងពីទង្វើតូចៗ ដែលពេញដោយសេចក្ដីស្រឡាញ់។ ម្យ៉ាងទៀត កាលណាអ្នកបង្ហាញសេចក្ដីស្រឡាញ់ចំពោះប្ដីប្រពន្ធកាន់តែខ្លាំង អ្នកនឹងកាន់តែមានអារម្មណ៍ស្រឡាញ់ចំពោះប្ដីប្រពន្ធអ្នកខ្លាំងឡើងៗ។

ដូច្នេះបើអ្នកចង់បានជីវិតអាពាហ៍ពិពាហ៍ដ៏មានសុភមង្គល ចូរសួរសំណួរមួយមកកាន់ខ្លួនឯងរាល់ថ្ងៃថា៖ «ថ្ងៃនេះតើខ្ញុំអាចធ្វើអ្វីបាន ដើម្បីបង្ហាញសេចក្ដីស្រឡាញ់ចំពោះប្ដីឬប្រពន្ធរបស់ខ្ញុំ?» ទង្វើតូចៗផុសចេញពីសេចក្ដីស្រឡាញ់ គឺជាគន្លឹះនៃអាពាហ៍ពិពាហ៍ដែលប្រកបដោយសុភមង្គល។

---

[3] សូមមើល *ការពន្យល់បន្ថែមអំពីអេភេសូរ ៥:២២-២៤* នៅក្នុងឧបសម្ព័ន្ធ។

ង. សំណួរពិភាក្សាជាមួយអ្នកប្រឹក្សា

1. តើអ្នកបានធ្វើកិច្ចការផ្ទះហើយ ឬនៅ? តើអ្នកគិតដូចម្តេច អំពីកិច្ចការផ្ទះនោះ?
2. តើចំណុចអ្វីខ្លះក្នុងមេរៀននេះ ដែលទាក់ទាញចំណាប់អារម្មណ៍អ្នក?
3. តើមានចំណុចអ្វីខ្លះ នៅក្នុងមេរៀននេះ ដែលអ្នកមិនទាន់យល់ទេ?
4. តើសេចក្តីស្រឡាញ់ពិតប្រាកដ ខុសពីក្តីស្រឡាញ់ក្លែងក្លាយយ៉ាងដូចម្តេចខ្លះ?
5. នៅក្នុងមេរៀនមានឃ្លាថា «ភាពអាត្មានិយម គឺជាសត្រូវដ៏ធំបំផុតនៃអាពាហ៍ពិពាហ៍របស់អ្នក។ នេះមានន័យថា ជារៀងរាល់ថ្ងៃ អ្នកនិងប្តីប្រពន្ធរបស់អ្នក ត្រូវតែខិតខំដើម្បីឆ្កាងភាពអាត្មានិយមនៅក្នុងចិត្តរបស់អ្នកផ្ទាល់។ បើមិនដូច្នោះទេ ភាពអាត្មានិយមនោះនឹងបំផ្លាញអាពាហ៍ពិពាហ៍របស់អ្នកជាក់ជាមិនខាន។» តើអ្នកយល់យ៉ាងណាដែរចំពោះប្រយោគនេះ?
6. តើភាពអាត្មានិយមរបស់អ្នកធ្លាប់ប៉ះពាល់ទំនាក់ទំនងរវាងអ្នក និងគូដណ្តឹងរបស់អ្នក យ៉ាងដូចម្តេចខ្លះ?
7. មេរៀននេះនិយាយថា ព្រះយេស៊ូវគឺជាប្រភព និងគំរូនៃសេចក្តីស្រឡាញ់ពិតប្រាកដ។ តើព្រះយេស៊ូវបានជួយអ្នកឲ្យរៀនពីរបៀបស្រឡាញ់គូដណ្តឹងរបស់អ្នក យ៉ាងដូចម្តេចខ្លះ?
8. តាមគំនិតរបស់អ្នក ហេតុអ្វីបានជាទង្វើតូចៗនៃសេចក្តីស្រឡាញ់ នាំឲ្យមានសុភមង្គលក្នុងអាពាហ៍ពិពាហ៍?
9. តើសកម្មភាពតូចៗមួយ ឬពីរយ៉ាងណាខ្លះ ដែលអ្នកអាចធ្វើក្នុងសប្តាហ៍នេះ ដើម្បីបង្ហាញក្តីស្រឡាញ់ចំពោះគូដណ្តឹងរបស់អ្នក?
10. តើមានចំណុចអ្វីផ្សេងទៀត ដែលអ្នកចង់សួរ ឬពិភាក្សា នៅថ្ងៃនេះ ឬទេ?

ច. កិច្ចការផ្ទះ

1. នៅលើក្រដាសតូចមួយ ចូរសរសេររឿងតូចៗចំនួន ១០-១៥ចំណុច ដែលធ្វើឲ្យអ្នកមានអារម្មណ៍ទទួលបានក្តីស្រលាញ់ពីគូដណ្តឹងរបស់អ្នក។ ចាប់ផ្តើមជាមួយប្រយោគ៖«ខ្ញុំមានអារម្មណ៍ជិតស្និទ្ធនឹងបង/អូននៅពេល ...។» ពេលសរសេរចប់ សូមយកក្រដាសនេះទៅឲ្យគូដណ្តឹងរបស់អ្នក។
2. សូមជួបជាមួយគូដណ្តឹងរបស់អ្នក ហើយសួរគ្នាទៅវិញទៅមកនូវសំណួរពិភាក្សាជាមួយដៃគូ ១៩-២៧ នៅក្នុងឧបសម្ព័ន្ធ។
3. សូមអធិស្ឋានជាមួយគ្នា យ៉ាងហោចណាស់ម្តងក្នុងមួយសប្តាហ៍។
4. សូមអានមេរៀនទី៤។

មេរៀនទី៤៖ ពីរនាក់ក្លាយជាសាច់ឈាមតែមួយ

«ដោយហេតុនោះ បានជាមនុស្សប្រុសនឹងលាចេញពីឪពុកម្ដាយខ្លួន ទៅនៅជាប់នឹងប្រពន្ធវិញ ហើយអ្នកទាំងពីរនោះនឹងត្រឡប់ជាសាច់តែមួយសុទ្ធ។» (លោកុប្បត្តិ ២:២៤)

ក. ការចាកចេញ និង ការជាប់គ្នាជាសាច់តែមួយ

អាពាហ៍ពិពាហ៍គឺជាចំណងដែលផ្សារភ្ជាប់មនុស្សពីរនាក់ (បុរសម្នាក់ និងស្ត្រីម្នាក់) ឲ្យក្លាយជាសាច់ឈាមតែមួយ ពេញមួយជីវិត។ ដើម្បីបង្កើតចំណងនេះបាន ព្រះគម្ពីរចែងថា បុរសត្រូវតែចាកចេញពីឪពុកម្ដាយខ្លួន ហើយទៅនៅជាប់នឹងប្រពន្ធ។ តើចំណុចនេះមានន័យដូចម្ដេច?

មុនពេលរៀបការ មនុស្សវ័យជំទង់ទូទៅត្រូវរស់នៅក្រោមអំណាចគ្រប់គ្រងរបស់ឪពុកម្ដាយខ្លួន។ ពួកគេពឹងផ្អែកលើឪពុកម្ដាយ ក្នុងការទទួលបានជំនួយផ្នែកម្ហូបអាហារ និងលុយកាក់ ក៏ដូចជាការគាំទ្រផ្សេងៗទៀតដែរ។ លើសពីនេះទៅទៀត ជាធម្មតា ទំនាក់ទំនងជិតស្និទ្ធបំផុតដែលមនុស្សទូទៅមាន គឺទំនាក់ទំនងរវាងពួកគេ និងសមាជិកក្នុងក្រុមគ្រួសាររបស់ពួកគេផ្ទាល់។ ទោះជាយ៉ាងណាក៏ដោយ នៅពេលដែលមនុស្សណាម្នាក់រៀបការហើយ រឿងនេះត្រូវតែផ្លាស់ប្ដូរ។

មុនពេលរៀបការ កូនកំលោះ និង កូនក្រមុំអាចពឹងផ្អែកលើឪពុកម្ដាយរបស់ខ្លួន។ បន្ទាប់ពីរៀបការរួច ពួកគេត្រូវរៀនពឹងផ្អែកលើព្រះជាម្ចាស់ និងពឹងផ្អែកលើគ្នាទៅវិញទៅមក។ មុនចូលក្នុងចំណងអាពាហ៍ពិពាហ៍ កូនកំលោះ និង កូនក្រមុំចុះចូលស្ដាប់បង្គាប់ឪពុកម្ដាយ ជាអ្នកគ្រប់គ្រងលើពួកគេ។ ប៉ុន្តែក្រោយពីរៀបការរួច ប្ដីប្រពន្ធត្រូវរៀនស្ដាប់ព្រះសូរសៀងរបស់ព្រះជាម្ចាស់ ហើយធ្វើការសម្រេចចិត្តរួមគ្នា។ ឪពុកម្ដាយគ្មានសិទ្ធិគ្រប់គ្រងលើពួកគេតទៅទៀតឡើយ។

បន្ទាប់ពីរៀបការរួច ទំនាក់ទំនងរបស់អ្នកជាមួយប្ដីឬប្រពន្ធរបស់អ្នក ត្រូវតែមានអាទិភាពលើទំនាក់ទំនងផ្សេងទៀតទាំងអស់ (រួមទាំងទំនាក់ទំនងរបស់អ្នកជាមួយឪពុកម្ដាយ និងបងប្អូនបង្កើតរបស់អ្នកផងដែរ)។ ប្ដីឬប្រពន្ធរបស់អ្នក ត្រូវតែក្លាយជាដៃគូជីវិត និងជាមិត្តជិតដិតបំផុតរបស់អ្នក។ នេះមានន័យថា អ្នកមិនត្រូវអនុញ្ញាតឲ្យនរណាម្នាក់ (រួមទាំងឪពុកម្ដាយ និងបងប្អូនបង្កើតរបស់អ្នក) ចូលមកឡូកឡំនឹងជីវិតអ្នក និងប្ដីឬប្រពន្ធរបស់អ្នកឡើយ។

ព្រះគម្ពីរបង្គាប់ប្ដីប្រពន្ធឲ្យចាកចេញពីឪពុកម្ដាយខ្លួន។ នេះមិនមានន័យថា គូស្វាមីភរិយាអាចបោះបង់ ឬមិនអើពើនឹងឪពុកម្ដាយរបស់ពួកគេឡើយ។ យើងត្រូវតែគោរពឪពុកម្ដាយរបស់យើងជានិច្ច (និក្ខមនំ ២០:១២) ស្ដាប់ដំបូន្មានរបស់ពួកគាត់ (និក្ខមនំ ១៨:២៤) និងជួយមើលថែឪពុកម្ដាយរបស់យើងនៅពេលពួកគាត់មានវ័យចំណាស់ផងដែរ (១ ធីម៉ូធេ ៥:៣)។ នៅពេលអ្នករៀបការរួច ទោះបីជាទំនាក់ទំនងរបស់អ្នកជាមួយឪពុកម្ដាយរបស់អ្នកត្រូវតែផ្លាស់ប្ដូរក៏ដោយ ក៏អ្នកត្រូវតែស្រឡាញ់ និងគោរពពួកគាត់ជារៀងរហូតដែរ។

ក្រោយរៀបការរួច មានស្វាមីភរិយាខ្លះរស់នៅក្នុងផ្ទះ ជាមួយឪពុកម្ដាយ។ ការនេះមិនមែនជារឿងខុសឆ្គងនោះទេ។ ក្នុងព្រះគម្ពីរ ពាក្យ «ចាកចេញ*ពីឪពុកម្ដាយខ្លួន*» និង «*ជាប់នឹងប្រពន្ធ*» សំដៅទៅលើការផ្លាស់ប្ដូរទំនាក់ទំនង មិនមែនសំដៅត្រង់ៗដល់ការផ្លាស់ប្ដូរទីកន្លែងរស់នៅនោះទេ។ ទោះបីជាអ្នករស់នៅទីណាក៏ដោយ អ្នកគប្បីការពារ និងផ្ដល់អាទិភាពដល់ទំនាក់ទំនងដែលអ្នកមានជាមួយនឹងប្ដី ឬប្រពន្ធរបស់អ្នក។

ខ. ចាកចេញពីរឿងអតីតកាល

បញ្ហាតែងកើតឡើងក្នុងជីវិតអាពាហ៍ពិពាហ៍ នៅពេលដែលស្វាមី ឬភរិយាមិនព្រមចាកចេញពីទំនាក់ទំនងក្នុងអតីតកាល ជាពិសេសប្រសិនបើពួកគេមិនបានកាត់ផ្ដាច់ទំនាក់ទំនងដែលពួកគេមានជាមួយគូស្នេហ៍ចាស់ ឲ្យដាច់ស្រឡះ។ ប្រសិនបើអ្នកមិនព្រមចាកចេញពីទំនាក់ទំនងដែលអ្នកមានកាលពីអតីតកាលនោះទេ ទំនាក់ទំនងទាំងនោះ នឹងមករំខានដល់ជីវិតអាពាហ៍ពិពាហ៍របស់អ្នកជាក់ជាមិនខាន។ វានឹងរារាំងអ្នក និងប្ដីឬប្រពន្ធរបស់អ្នក មិនឲ្យមានទំនាក់ទំនងជិតស្និទ្ធជាមួយគ្នាបានឡើយ។

ប្រសិនបើអ្នកធ្លាប់មានទំនាក់ទំនងស្នេហាពីមុនមក ខាងក្រោមនេះជាការណែនាំមួយចំនួនៈ

- ប្រមូលចោល ឬលុបរូបថតរបស់គូស្នេហ៍ចាស់របស់អ្នក។
- ប្រមូលឬលុបសំបុត្រសារសងស្នេហា ឬក៏សារនានាដែលគូស្នេហ៍ចាស់របស់អ្នកធ្លាប់ផ្ញើមកអ្នក។
- ប្រមូលលក់ ឬបរិច្ចាគរបស់នានាដែលធ្វើឲ្យអ្នកនឹករលឹកដល់គូស្នេហ៍ចាស់របស់អ្នក។
- កុំទាក់ទងសង្សារចាស់របស់អ្នកតទៅទៀត។
- ប្រសិនបើសង្សារចាស់របស់អ្នកទាក់ទងអ្នក អ្នកត្រូវប្រាប់ប្ដីឬប្រពន្ធរបស់អ្នកភ្លាមៗ។
- កុំនិយាយពីសង្សារចាស់របស់អ្នកច្រើនពេក ឬប្រៀបធៀបពួកគេទៅនឹងស្វាមីភរិយារបស់អ្នក។

មុនពេលរៀបការ អ្នកគួរតែប្រាប់គូដណ្ដឹងរបស់អ្នក អំពីទំនាក់ទំនងពីមុនដែលអ្នកធ្លាប់មាន។ ពេលខ្លះរឿងទាំងនេះអាចពិបាកនិយាយ។ ជាពិសេសប្រសិនបើទំនាក់ទំនងអតីតកាលទាំងនោះមិនបរិសុទ្ធ អ្នកគួរតែសុំការអត់ទោសពីគូដណ្ដឹងរបស់អ្នក។ មិនថាមានរឿងអ្វីកើតឡើងក៏ដោយ វាពិតជាសំខាន់ណាស់ដែលអ្នកមិនត្រូវលាក់បាំងអ្វីពីគ្នាទៅវិញទៅមក។

គ. អាពាហ៍ពិពាហ៍របស់យើង ទ្រព្យសម្បត្តិរបស់យើង

នៅក្នុងចំណងអាពាហ៍ពិពាហ៍ មនុស្សពីរនាក់ត្រឡប់មកជាសាច់តែមួយ។ អ្វីៗដែលប្ដីមាន គឺត្រូវចែកជាមួយនឹងប្រពន្ធ ហើយអ្វីគ្រប់យ៉ាងដែលប្រពន្ធមាន នាងក៏ចែករំលែកជាមួយប្ដីដែរ។ ពួកគេចែករំលែកដួងចិត្ត រូបកាយ ហើយសូម្បីតែទ្រព្យសម្បត្តិ ក៏ពួកគេចែករំលែកជាមួយគ្នាដែរ។ ដូចដែលយើងបានឃើញនៅក្នុងមេរៀនទី២ ការរួបរួមរវាងប្ដីប្រពន្ធនេះ គឺជារូបភាពតូចមួយនៃទំនាក់ទំនងរវាងព្រះគ្រីស្ទ និងក្រុមជំនុំ។

ដើម្បីរស់នៅជាសាច់ឈាមតែមួយបាន ប្ដីប្រពន្ធត្រូវរៀនគ្រប់គ្រងទ្រព្យសម្បត្តិរួមគ្នា។ ក្នុងអាពាហ៍ពិពាហ៍ លែងមានពាក្យ «លុយរបស់ខ្ញុំ» ទៀតហើយ មានតែ «លុយរបស់យើង»។ ទ្រព្យសម្បត្តិទាំងអស់របស់អ្នកក្លាយជា

កម្មសិទ្ធិរបស់ប្ដីឬប្រពន្ធរបស់អ្នក។ ហើយប្រសិនបើប្ដីឬប្រពន្ធរបស់អ្នកមានបំណុល បំណុលរបស់ពួកគេក៏ក្លាយជាបំណុលរបស់អ្នកដែរ។

ពេលខ្លះប្ដីនិងប្រពន្ធអាចមានការខ្វែងគំនិតគ្នាអំពីរបៀបប្រើប្រាស់ និងគ្រប់គ្រងថវិកា។ បញ្ហាបែបនេះអាចធ្វើឲ្យគូស្វាមីភរិយាឈ្លោះប្រកែកគ្នាបាន។ ក្នុងករណីខ្លះ បញ្ហានេះអាចនាំឲ្យប្ដីប្រពន្ធ ឈានទៅដល់ការលែងលះគ្នាក៏មាន។ ប៉ុន្តែ ប្រសិនបើគូស្វាមីភរិយាចេះបន្ទាបខ្លួន អធិស្ឋាន និងស្ដាប់គ្នាទៅវិញទៅមក នោះព្រះជាម្ចាស់អាចប្រើបញ្ហាទាំងនេះ ដើម្បីពង្រឹងទំនាក់ទំនងរបស់ពួកគេឲ្យកាន់តែរឹងមាំ ហើយបង្រៀនពួកគេបន្ថែមទៀតអំពីអត្ថន័យនៃការរស់នៅជាមួយគ្នាជាសាច់ឈាមតែមួយ។

ខាងក្រោមនេះជាយោបល់មួយចំនួន អំពីការគ្រប់គ្រងថវិកាក្នុងចំណងអាពាហ៍ពិពាហ៍៖

- **យកព្រះជាម្ចាស់ជាលេខមួយ៖** ថ្វាយដង្វាយមួយភាគដប់ ព្រមទាំងស្វែងរកព្រះហឫទ័យរបស់ព្រះអង្គជាមួយគ្នា អំពីរបៀបដែលអ្នកទាំងពីរអាចប្រើប្រាស់លុយ និងទ្រព្យសម្បត្តិរបស់អ្នក។
- **ធ្វើការសម្រេចចិត្តអំពីរឿងថវិកាជាមួយគ្នា៖** សូមចងចាំថា វាមិនមែនជាទ្រព្យសម្បត្តិរបស់អ្នកតែម្នាក់ឯងប៉ុណ្ណោះទេ។ ដូច្នេះ សូមកុំធ្វើការសម្រេចចិត្តទាក់ទងនឹងរឿងថវិកាតែម្នាក់ឯង។
- **រៀបចំបង្កើតកញ្ចប់ថវិកាប្រចាំគ្រួសារ**[4]
- **មិនត្រូវបង្កឲ្យមានការភ្ញាក់ផ្អើលទេ៖** មុននឹងចាយលុយ ខ្ចីបំណុល ឬក៏ជូនថវិកាដើម្បីជួយបងប្អូនរបស់អ្នក អ្នកគប្បីត្រូវពិភាក្សាជាមួយប្ដីឬប្រពន្ធអ្នកជាមុនសិន។

ឃ. ទម្លាប់សំខាន់៖ បង្កើតឲ្យមានពេលវេលាសម្រាប់អាពាហ៍ពិពាហ៍របស់អ្នក

ព្រះជាម្ចាស់គាប់ព្រះហឫទ័យឲ្យប្ដី និងប្រពន្ធរួបរួមគ្នាជានិច្ច។ នេះមានន័យថា អ្នកត្រូវយកអាពាហ៍ពិពាហ៍របស់អ្នកជាអាទិភាព។ ទំនាក់ទំនងដែលអ្នកមានជាមួយប្ដីប្រពន្ធរបស់អ្នក គឺជាទំនាក់ទំនងដែលមានសារៈសំខាន់បំផុតនៅក្នុងជីវិតរបស់អ្នក បន្ទាប់ពីទំនាក់ទំនងដែលអ្នកមានជាមួយនឹងព្រះជាម្ចាស់។

មនុស្សភាគច្រើនតែងជាប់រវល់ ចាប់ពីព្រឹករហូតដល់យប់។ ដូចនេះហើយ ប្រសិនបើស្វាមីភរិយា មិនឆ្លៀតពេលជាមួយគ្នា មិនយូរមិនឆាប់ ពួកគេនឹងរសាត់ដាច់ចេញពីគ្នា។ ការឆ្លៀតពេលវេលាសម្រាប់អាពាហ៍ពិពាហ៍មានន័យថា ជាការកំណត់ពេលវេលាយ៉ាងទៀងទាត់សម្រាប់ពង្រឹងទំនាក់ទំនងរបស់អ្នក។ ជាឧទាហរណ៍ គូស្វាមីភរិយាខ្លះឆ្លៀតពេល ១៥នាទីដើម្បីជជែកគ្នា និងអធិស្ឋានជាមួយគ្នាជារៀងរាល់ថ្ងៃ។ គូស្វាមីភរិយាខ្លះទៀតឆ្លៀតពេលមួយម៉ោងជារៀងរាល់សប្ដាហ៍ ដើម្បីដើរលេងលំហែអារម្មណ៍ជាមួយគ្នា។

អ្នក និងប្ដីឬប្រពន្ធរបស់អ្នក គួររៀបចំផែនការតាមពេលវេលាដែលល្អបំផុតសម្រាប់អ្នក។ ប្រសិនបើអ្នក និងប្ដីប្រពន្ធអ្នកមិនចង់បែកគ្នាបន្តិចម្ដងៗទេ អ្នកត្រូវតែឆ្លៀតពេលវេលាជាទៀងទាត់ សម្រាប់ពង្រឹងចំណងអាពាហ៍ពិពាហ៍របស់អ្នក។

---

[4] សូមមើល *តារាងរៀបចំថវិកាប្រចាំគ្រួសារ* នៅក្នុងឧបសម្ព័ន្ធ។

ង. សំណួរពិភាក្សាជាមួយអ្នកប្រឹក្សា

1. តើអ្នកបានធ្វើកិច្ចការផ្ទះហើយ ឬនៅ? តើអ្នកគិតដូចម្តេច អំពីកិច្ចការផ្ទះនោះ?
2. តើចំណុចអ្វីខ្លះក្នុងមេរៀននេះ ដែលទាក់ទាញចំណាប់អារម្មណ៍អ្នក?
3. តើមានចំណុចអ្វីខ្លះ នៅក្នុងមេរៀននេះ ដែលអ្នកមិនទាន់យល់ទេ?
4. សូមជួយរៀបរាប់អំពីទំនាក់ទំនងរវាងអ្នក និងឪពុកម្តាយ ឬបងប្អូនរបស់អ្នក។
5. តើអ្នករំពឹងថាទំនាក់ទំនងទាំងទាំងនេះ (ឪពុកម្តាយ និងបងប្អូន) នឹងផ្លាស់ប្តូរយ៉ាងដូចម្តេចបន្ទាប់ពីអ្នករៀបការរួច?
6. តើវាមានន័យយ៉ាងណាសម្រាប់អ្នក ចំពោះការចាកចេញពីគ្រួសាររបស់អ្នក ហើយនៅជាប់នឹងប្តីប្រពន្ធរបស់អ្នក?
7. បន្ទាប់ពីរៀបការហើយ តើអ្នកនឹងបង្ហាញសេចក្តីស្រឡាញ់ និងការគោរពចំពោះឪពុកម្តាយ (និងសាច់ថ្លៃ) យ៉ាងដូចម្តេច?
8. តើអ្នកធ្លាប់មានសង្សាចាស់ឬទេ? បើដូច្នេះ តើអ្នកបាននិយាយជាមួយគូដណ្តឹងរបស់អ្នកអំពីទំនាក់ទំនងទាំងនេះហើយឬនៅ?
9. បើគូដណ្តឹងអ្នកធ្លាប់មានទំនាក់ទំនងស្នេហាពីមុន តើអ្នកជឿជាក់ថាគាត់បានដើរចេញពីទំនាក់ទំនងនោះទាំងស្រុងហើយឬនៅ? ហេតុអ្វី?
10. តើមាននរណាម្នាក់ដែលអ្នកខ្លាចថា អាចនឹងចូលជ្រៀតជ្រែកជីវិតអ្នកនិងប្តីប្រពន្ធរបស់អ្នកនៅថ្ងៃណាមួយដែរឬទេ?
11. បន្ទាប់ពីរៀបការហើយ តើអ្នកមានគម្រោងគ្រប់គ្រងលុយរបស់អ្នកដោយរបៀបណា?
12. បន្ទាប់ពីអ្នករៀបការហើយ តើអ្នកចង់បង្កើតទម្លាប់ថ្មីអ្វីខ្លះ ជាប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ប្រចាំខែ ដែលអ្នក និងប្តីប្រពន្ធរបស់អ្នកនឹងធ្វើ ដើម្បីផ្តល់អាទិភាពដល់ទំនាក់ទំនងរបស់អ្នកទាំងពីរ?
13. តើមានចំណុចអ្វីផ្សេងទៀត ដែលអ្នកចង់សួរ ឬពិភាក្សា នៅថ្ងៃនេះ ឬទេ?

ច. កិច្ចការផ្ទះ

1. សូមពិភាក្សាជាមួយគូដណ្តឹងរបស់អ្នកនូវអ្វីដែលអ្នកនឹងធ្វើ ដើម្បីផ្តល់អាទិភាពដល់ទំនាក់ទំនងរបស់អ្នកបន្ទាប់ពីអ្នករៀបការរួច។ សូមធ្វើការជាមួយគ្នា ដើម្បីបង្កើតផែនការ សម្រាប់សកម្មភាពប្រចាំថ្ងៃ ប្រចាំសប្តាហ៍ និងប្រចាំខែ សម្រាប់រយៈពេលប្រាំមួយខែដំបូង បន្ទាប់ពីរៀបអាពាហ៍ពិពាហ៍។
2. សូមជួបជាមួយគូដណ្តឹងរបស់អ្នក ហើយសួរគ្នាទៅវិញទៅមកនូវសំណួរពិភាក្សាជាមួយដៃគូ ២៨-៣៦ នៅក្នុងឧបសម្ព័ន្ធ។
3. សូមអធិស្ឋានជាមួយគ្នា យ៉ាងហោចណាស់ម្តងក្នុងមួយសប្តាហ៍។
4. សូមអានមេរៀនទី៥។

មេរៀនទី៥៖ ការដោះស្រាយទំនាស់

«មានពរហើយ អ្នកដែលបង្កើតសន្តិភាព ដ្បិតពួកគេនឹងត្រូវបានហៅថាកូនរបស់ព្រះ។» (ម៉ាថាយ ៥:៩)

ក. ថ្នាក់រៀនរបស់ព្រះគ្រីស្ទ

ប្ដី ឬប្រពន្ធរបស់អ្នក ជាព្រះពរយ៉ាងល្អអស្ចារ្យ ដែលព្រះជាម្ចាស់បានប្រទានមកកាន់អ្នក (សុភាសិត ១៨:២២)។ ប៉ុន្តែវាមិនមែនមានន័យថា ការរស់នៅជាមួយគ្នាជាប្ដីប្រពន្ធ តែងតែងាយស្រួលនោះទេ។ ពេលខ្លះជីវិតអាពាហ៍ពិពាហ៍អាចជួបប្រទះនឹងការលំបាក។

គ្មានប្ដីប្រពន្ធមួយគូណា ដែលមានចរិតលក្ខណៈដូចគ្នាបេះបិទនោះទេ។ អ្នក និងគូដណ្ដឹងរបស់អ្នក គឺជាមនុស្សខុសគ្នា មានប្រវត្តិខុសគ្នា បុគ្គលិកលក្ខណៈខុសគ្នា និងចិត្តគំនិតផ្សេងពីគ្នាផងដែរ។ នេះមានន័យថា គ្រប់គូស្វាមីភរិយាទាំងអស់ នឹងមានការខ្វែងគំនិតគ្នាខ្លះៗ។

លើសពីនេះទៅទៀត ប្ដីប្រពន្ធគ្រប់រូបសុទ្ធតែមានបាប។ វាជាការពិត ដែលព្រះជាម្ចាស់ធ្វើការ ពីមួយថ្ងៃទៅមួយថ្ងៃ ក្នុងការកែប្រែកូនរបស់ទ្រង់ ឲ្យកាន់តែមានលក្ខណៈល្អ ដូចព្រះអង្គ។ ប៉ុន្តែគ្មានយើងណាម្នាក់ល្អឥតខ្ចោះនោះទេ។ ហេតុនេះហើយ ពេលខ្លះអ្នកអាចនឹងប្រព្រឹត្តអំពើខុសឆ្គងទាស់នឹងប្ដីឬប្រពន្ធរបស់អ្នក ហើយគាត់ក៏អាចធ្វើខុសទាស់នឹងអ្នកវិញផងដែរ។

ជីវិតអាពាហ៍ពិពាហ៍មិនតែងតែងាយស្រួលនោះទេ ប៉ុន្តែព្រះជាម្ចាស់ប្រើជីវិតជាគូនេះ សម្រាប់ជាប្រយោជន៍ដល់យើង។ ព្រះជាម្ចាស់ប្រើការលំបាក និងការខ្វែងគំនិតគ្នាក្នុងអាពាហ៍ពិពាហ៍ជាថ្នាក់រៀនមួយ ដើម្បីបង្រៀនយើងពីរបៀបឲ្យចេះស្រឡាញ់គ្នា ដូចរបៀបដែលទ្រង់ស្រឡាញ់យើង។ ជីវិតអាពាហ៍ពិពាហ៍គ្រីស្ទបរិស័ទ គឺជាថ្នាក់រៀនរបស់ព្រះគ្រីស្ទ ដែលតែងតែផ្ដល់ឱកាសឲ្យយើងចេះអត់ទោសគ្នា ដូចជារបៀបដែលទ្រង់អត់ទោសយើង ហើយឲ្យយើងចេះលះបង់ខ្លួន ដូចរបៀបដែលព្រះយេស៊ូវបានលះបង់អង្គទ្រង់សម្រាប់យើងរាល់គ្នាដែរ។

ប្រសិនបើអ្នកមានដួងចិត្តទន់ចំពោះការអប់រំរបស់ព្រះជាម្ចាស់ ទ្រង់នឹងប្រើអាពាហ៍ពិពាហ៍របស់អ្នក ដើម្បីបង្រៀនអ្នកបន្ថែមទៀតអំពីការក្រាប់តាមព្រះយេស៊ូវ ច្រើនជាជាងមេរៀនដែលអ្នកអាចរៀននៅសាលាព្រះគម្ពីរទៅទៀត។

ខ. ចាប់ផ្ដើមជាមួយខ្លួនអ្នក

ជាធម្មតាពេលគូស្នេហ៍មានបញ្ហា ពួកគេតែងតែបន្ទោសគ្នាទៅវិញទៅមក។ ពួកគេទាំងពីរគិតថា «វាមិនមែនជាកំហុសរបស់ខ្ញុំទេ។ វាគឺជាកំហុសរបស់គាត់!» ការគិតបែបនេះ មិនដែលនាំទៅរកលទ្ធផលល្អទេ។

ព្រះយេស៊ូវបានបង្រៀនថា ជំហានដំបូងដើម្បីដោះស្រាយទំនាស់ គឺត្រូវចាប់ផ្ដើមពីខ្លួនឯងជាមុនសិន (ម៉ាថាយ ៧:១-៥)។ ជំនួសឲ្យការរិះគន់ប្ដីឬប្រពន្ធរបស់អ្នក អ្នកត្រូវពិនិត្យពិច័យមើលខ្លួនឯងជាមុនសិន។ អ្នកត្រូវសុំជំនួយពីព្រះជាម្ចាស់ ដោយការបន្ទាបខ្លួន សូមទ្រង់បង្ហាញអ្នកពីរបៀបដែលអ្នកបានរួមចំណែកក្នុងបញ្ហានេះ។ បន្ទាប់មក អ្នកត្រូវសារភាពអំពើបាបរបស់អ្នកចំពោះព្រះជាម្ចាស់ ហើយសុំឲ្យទ្រង់កែប្រែអ្នក។ បន្ទាប់មក

ប្រសិនបើព្រះជាម្ចាស់បង្ហាញអ្នកថា អ្នកបានប្រព្រឹត្តអំពើខុសឆ្គងណាមួយ ឬច្រើន ដាក់ប្ដីប្រពន្ធរបស់អ្នកមែន អ្នកគួរទៅសុំទោសគាត់។

ឧទាហរណ៍ ប្រសិនបើមានបញ្ហារវាងអ្នក និងប្ដីឬប្រពន្ធរបស់អ្នក ទោះបីជាប្ដីឬប្រពន្ធរបស់អ្នកបានបង្កបញ្ហាដល់ទៅ ៩៩% ក៏ដោយ អ្នកនៅតែត្រូវចាប់ផ្ដើមជាមួយខ្លួនអ្នកដែរ។ អ្នកត្រូវទទួលខុសត្រូវដោយចិត្តរាបទាបចំពោះចំណែកបញ្ហា ១% របស់អ្នក។ ប្រសិនបើអ្នកធ្វើបែបនេះ នោះព្រះវិញ្ញាណបរិសុទ្ធអាចប្រើគំរូរបស់អ្នក ដើម្បីនាំប្ដីឬប្រពន្ធរបស់អ្នកឲ្យទទួលខុសត្រូវចំពោះចំណែកបញ្ហារបស់គាត់ផងដែរ។

អ្នកមិនអាចផ្លាស់ប្ដូរប្ដីប្រពន្ធរបស់អ្នកបានទេ។ មានតែព្រះជាម្ចាស់ទេ ដែលអាចផ្លាស់ប្រែមនុស្សបាន។ ប៉ុន្តែប្រសិនបើអ្នកអនុញ្ញាតឲ្យព្រះវិញ្ញាណបរិសុទ្ធផ្លាស់ប្រែអ្នកជាមុន នោះគ្រួសាររបស់អ្នកនឹងប្រសើរឡើង។ ជំហានដំបូងដើម្បីដោះស្រាយបញ្ហាណាមួយរវាងអ្នក និងប្ដីឬប្រពន្ធរបស់អ្នក គឺអ្នកត្រូវចាប់ផ្ដើមជាមួយខ្លួនអ្នកជាមុន។

គ. របៀបចាស់ និងរបៀបថ្មី

ក្នុងអាពាហ៍ពិពាហ៍ ពេលខ្លះនឹងមានការខ្វែងគំនិតគ្នា រហូតដល់អាចមានការឈ្លោះប្រកែកគ្នាក៏មាន។ ទោះជាយ៉ាងណាក៏ដោយ បញ្ហាទាំងនេះមិនគួរដល់ថ្នាក់បង្កផលប៉ះពាល់ ឬបំផ្លិចបំផ្លាញទំនាក់ទំនងរបស់អ្នកនោះទេ។ អ្វីៗទាំងអស់ អាស្រ័យលើរបៀបដែលអ្នក និងប្ដីឬប្រពន្ធរបស់អ្នកដោះស្រាយទំនាស់ជាមួយគ្នា។ តើអ្នកឆ្លើយតបនឹងបញ្ហាដោយពឹងផ្អែកលើព្រះវិញ្ញាណបរិសុទ្ធ ឬតាមរបៀបចាស់របស់សាច់ឈាម?

ពេលអ្នកមានបញ្ហាអាពាហ៍ពិពាហ៍ អ្នកមិនត្រូវធ្វើតាមរបៀបចាស់ ដូចជា៖

- ជេរប្រមាថ មើលងាយ ឬបង្អាប់ប្ដី ឬប្រពន្ធរបស់អ្នកទេ
- ស្រែក ឬប្រើអំពើហឹង្សា
- គំរាមលែងលះ
- ធ្វើពុតដូចជាមិនមានបញ្ហាអ្វី
- មិនអើពើនឹងប្ដី ឬប្រពន្ធរបស់អ្នក
- បដិសេធមិនព្រមនិយាយរកគ្នា ឬមិនបើកចិត្តស្ដាប់
- រត់គេចវេសទៅឲ្យឆ្ងាយ
- ត្អូញត្អែរ រអ៊ូរទាំ ឬនិយាយដើមប្ដីប្រពន្ធរបស់អ្នកទៅកាន់អ្នកដទៃ
- បន្តលើកយកបញ្ហាចាស់មកនិយាយម្ដងហើយ ម្ដងទៀត

កុំឆ្លើយតបនឹងបញ្ហាតាមរបៀបចាស់ (កូល៉ុស ៣:៨-៩)។ ផ្ទុយទៅវិញ ចូរសុំព្រះជាម្ចាស់ឲ្យជួយអ្នក និងប្ដីប្រពន្ធរបស់អ្នកដោះស្រាយបញ្ហាតាមរបៀបថ្មីនៃព្រះវិញ្ញាណបរិសុទ្ធ (កូល៉ុស ៣:១២-១៤)។ បើអ្នកធ្វើដូច្នេះ ព្រះជាម្ចាស់នឹងប្រើបញ្ហាទាំងនេះ ដើម្បីពង្រឹងចំណងអាពាហ៍ពិពាហ៍របស់អ្នក ហើយផ្លាស់ប្ដូរអ្នកទាំងពីរឲ្យកាន់តែមានលក្ខណៈដូចព្រះយេស៊ូវ។

ឃ. ទម្លាប់សំខាន់៖ ការដោះស្រាយបញ្ហា

គូស្វាមីភរិយាដែលចេះរស់នៅប្រកបដោយសុភមង្គល មិនខ្លាចបញ្ហាខ្វែងគំនិតគ្នានោះទេ ពីព្រោះពួកគេបានរៀនពីរបៀបសហការគ្នាដើម្បីដោះស្រាយបញ្ហា។ នេះគឺជាជំហានសាមញ្ញមួយចំនួន ដើម្បីជួយអ្នកក្នុងការដោះស្រាយបញ្ហា៖

1. **ទទួលស្គាល់៖** ទទួលស្គាល់ថាមានបញ្ហា។ ទោះបីមានតែប្ដីឬប្រពន្ធតែម្ខាង ដែលគិតថាមានបញ្ហាក្នុងទំនាក់ទំនងក៏ដោយ ក៏ប្ដីប្រពន្ធទាំងពីរត្រូវព្យាយាមដោះស្រាយបញ្ហាជាមួយគ្នា។

2. **កាលវិភាគ៖** ជ្រើសរើសពេលវេលា និងទីកន្លែងសមរម្យ ដើម្បីនិយាយអំពីបញ្ហានោះ។ ព្យាយាមកុំទុកបញ្ហាលើសពី ២៤ ម៉ោង ក្នុងការដោះស្រាយបញ្ហា (អេភេសូរ ៤:២៦)។

3. **រៀបចំខ្លួនអ្នក៖** សួរខ្លួនឯងដោយអធិស្ឋានថា «ហេតុអ្វីបានជាខ្ញុំតូចចិត្ត?» «តើខ្ញុំបានរួមចំណែកបង្កបញ្ហានេះដោយរបៀបណា?» «តើខ្ញុំអាចនិយាយជាមួយប្ដីឬប្រពន្ធរបស់ខ្ញុំដោយរបៀបណា ដែលគាត់អាចទទួលពាក្យរបស់ខ្ញុំបាន?»

4. **ស្ដាប់៖** ស្ដាប់ដោយចិត្តអត់ធ្មត់ នូវអ្វីដែលប្ដីឬប្រពន្ធរបស់អ្នកនិយាយ។ កុំនិយាយបង្អាក់។ ទោះបីជាអ្នកមិនយល់ស្របជាមួយប្ដីឬប្រពន្ធរបស់អ្នកក៏ដោយ ចូរព្យាយាមយល់ពីជំហររបស់គាត់ជាមុនសិន។

5. **គិតមុននឹងនិយាយ៖** *«តែដោយកាន់តាមសេចក្ដីពិតដោយសេចក្ដីស្រឡាញ់វិញ...មិនត្រូវឲ្យមានពាក្យអាក្រក់ណាមួយ ចេញពីមាត់អ្នករាល់គ្នាឡើយ ចូរបញ្ចេញតែពាក្យណាដែលល្អៗ សម្រាប់នឹងស្អាងចិត្តតាមត្រូវការ ដើម្បីឲ្យបានផ្ដល់ព្រះគុណដល់អស់អ្នកដែលស្ដាប់»* (អេភេសូរ ៤:១៥, ២៩)។

6. **បើចាំបាច់ ត្រូវសម្រាកសិន៖** ពេលកំពុងនិយាយ ប្រសិនបើអ្នក ឬប្ដីឬប្រពន្ធរបស់អ្នកចាប់ផ្ដើមមានចិត្តក្ដៅក្រហាយ វាអាចមានប្រយោជន៍ក្នុងការសម្រាកបន្តិចសិន (រយៈពេល ១៥ នាទី ឬពីរបីម៉ោង)។ យ៉ាងណាមិញ មុនពេលឈប់សម្រាក អ្នកទាំងពីរគួរសម្រេចចិត្តថាពេលណាដែលអ្នកនឹងជួបគ្នាម្ដងទៀត ដើម្បីបន្តនិយាយ។ អ្នកមិនត្រូវរត់ចេញពីប្ដីប្រពន្ធ ដោយកំហឹងឡើយ។

7. **ធ្វើការជាមួយគ្នា៖** ក្នុងការនិយាយគ្នា អ្នកមិនត្រូវព្យាយាមដើម្បីយកឈ្នះក្នុងការឈ្លោះប្រកែកគ្នា ឬធ្វើឲ្យប្ដីឬប្រពន្ធរបស់អ្នក ស្ដាប់បង្គាប់តាមអ្នកនោះទេ។ ផ្ទុយទៅវិញ គោលដៅរបស់អ្នកគួរតែជាការស្វែងរកដំណោះស្រាយដែលគាប់ព្រះហឫទ័យព្រះជាម្ចាស់ ហើយជាដំណោះស្រាយសមស្របសម្រាប់ទាំងអ្នកទាំងពីរ។

ប្រសិនបើអ្នកដោះស្រាយបញ្ហាតាមវិធីនេះ ទំនាក់ទំនងរបស់អ្នកនឹងកាន់តែរឹងមាំ។

ង. សំណួរពិភាក្សាជាមួយអ្នកប្រឹក្សា

1. តើអ្នកបានធ្វើកិច្ចការផ្ទះហើយ ឬនៅ? តើអ្នកគិតដូចម្ដេច អំពីកិច្ចការផ្ទះនោះ?
2. តើចំណុចអ្វីខ្លះក្នុងមេរៀន ដែលទាក់ទាញចំណាប់អារម្មណ៍អ្នក?
3. តើមានចំណុចអ្វីខ្លះ នៅក្នុងមេរៀននេះ ដែលអ្នកមិនទាន់យល់ទេ?
4. តើព្រះជាម្ចាស់ប្រើការលំបាក និងការខ្វែងគំនិតគ្នាក្នុងអាពាហ៍ពិពាហ៍យ៉ាងដូចម្ដេច ដើម្បីធ្វើឲ្យយើងមានចិត្តកាន់តែដូចព្រះគ្រីស្ទ?
5. នៅក្នុងមេរៀននេះមានឃ្លាថា៖ «ព្រះយេស៊ូវបានបង្រៀនថា ជំហានដំបូងដើម្បីដោះស្រាយទំនាស់ គឺត្រូវចាប់ផ្ដើមពីខ្លួនឯងជាមុនសិន (ម៉ាថាយ ៧:១-៥)។» តើអ្នកគិតថាឃ្លានេះ មានន័យយ៉ាងណា? ហេតុអ្វីចំណុចនេះសំខាន់ម្ល៉េះ?
6. ពេលអ្នកមានបញ្ហាក្នុងទំនាក់ទំនងរបស់អ្នក តើអ្នកធ្លាប់ប្រព្រឹត្តតាមរបៀបចាស់នៃសាច់ឈាមដែរឬទេ? បើដូច្នេះ តើអ្នកបានធ្វើអ្វីខ្លះ?
7. តើអ្នកអាចធ្វើអ្វី ដើម្បីឆ្លើយតបនឹងបញ្ហាក្នុងអាពាហ៍ពិពាហ៍តាមរបៀបថ្មីនៃព្រះវិញ្ញាណ ហើយមិនធ្វើតាមរបៀបចាស់នៃសាច់ឈាមតទៅទៀត?
8. ក្នុងការដោះស្រាយបញ្ហាជាដៃគូ តើអ្នក និងគូដណ្ដឹងរបស់អ្នកមានចំណុចខ្លាំងអ្វីខ្លះ និងចំណុចខ្សោយអ្វីខ្លះ?
9. ក្នុងចំណោមជំហានទាំងប្រាំពីរ ពីរបៀបដោះស្រាយបញ្ហាដែលបានរាយរាប់ខាងលើ តើជំហានមួយណាដែលអ្នកត្រូវខំរៀនជាងគេ?
10. តើមានចំណុចអ្វីផ្សេងទៀត ដែលអ្នកចង់សួរ ឬពិភាក្សាគ្នា នៅថ្ងៃនេះ ឬទេ?

ច. កិច្ចការផ្ទះ

1. សូមពិភាក្សាជាមួយគូដណ្ដឹងរបស់អ្នក ពីរបៀបដែលអ្នកនឹងដោះស្រាយទំនាស់ក្នុងទំនាក់ទំនងរបស់អ្នក។ ពេលមានបញ្ហាលើក្រោយ តើអ្នកនឹងធ្វើយ៉ាងណាដើម្បីដោះស្រាយបញ្ហានោះ?
2. សូមជួបជាមួយគូដណ្ដឹងអ្នក ដើម្បីរៀបចំបញ្ជីពីចំណុចដែលអ្នកសន្យាថានឹងមិននិយាយ និងអ្វីដែលអ្នកសន្យាថានឹងមិនធ្វើ ទោះក្នុងកាលៈទេសៈណាក៏ដោយ មិនថាអ្នកខឹងគ្នាខ្លាំងប៉ុណ្ណានោះទេ។
3. សូមជួបជាមួយគូដណ្ដឹងរបស់អ្នក ហើយសួរគ្នាទៅវិញទៅមកនូវសំណួរពិភាក្សាជាមួយដៃគូ ៣៧-៣៩ នៅក្នុងឧបសម្ព័ន្ធ។
4. សូមអធិស្ឋានជាមួយគ្នា យ៉ាងហោចណាស់ម្ដងក្នុងមួយសប្ដាហ៍។
5. សូមអានមេរៀនទី៦។

មេរៀនទី៦៖ ដួងចិត្តតែមួយ និងសាច់ឈាមតែមួយ (ការរួមដំណេក)

«សូមឲ្យរន្ធទឹកឯងបានពរ ចូរឲ្យឯងបានរីករាយចំពោះប្រពន្ធ ដែលបានគ្នាពីកាលក្រមុំកំលោះចុះ ប្រៀបដូចជាក្តាន់ញី ដែលគួរស្រឡាញ់ និងប្រើសញីសមសួន ត្រូវឲ្យដោះរបស់នាងបានបំពេញចិត្តឯងជាដរាប ហើយអ្នកត្រូវឈ្លក់ចិត្តនឹងសេចក្តីស្រឡាញ់ របស់នាងជានិច្ចផង។» (សុភាសិត ៥:១៨-១៩)

ក. អាក្រាតទទេ ឥតមានសេចក្តីអៀនខ្មាសឡើយ

ការរួមដំណេក គឺជាការសបញ្ជាក់ពីភាពស្និទ្ធស្នាលបំផុតនៃសេចក្តីស្រឡាញ់ និងការរួបរួមរបស់ប្តីប្រពន្ធ។ គ្រប់ពេលដែលប្តីប្រពន្ធរួមភេទជាមួយគ្នា បានន័យថាប្តីកំពុងប្រគល់ខ្លួនឯង (ទាំងផ្លូវកាយ និងផ្លូវចិត្ត) ឲ្យទៅប្រពន្ធ ហើយប្រពន្ធក៏ប្រគល់ខ្លួនឯង (ទាំងផ្លូវកាយ និងផ្លូវចិត្ត) ឲ្យដល់ប្តីដែរ។ ការរួមដំណេក គឺជាសញ្ញាសម្គាល់ដ៏ជ្រាលជ្រៅបំផុតនៃសម្ព័ន្ធមេត្រីអាពាហ៍ពិពាហ៍។

ការរួមភេទ រវាងប្តីប្រពន្ធមិនមែនជាអំពើបាប ឬទង្វើស្មោកគ្រោកនោះឡើយ។ ផ្ទុយទៅវិញ ក្នុងអាពាហ៍ពិពាហ៍ ការរួមដំណេក គឺជាព្រះពរដ៏អស្ចារ្យពីព្រះជាម្ចាស់ ដែលអាចនាំទៅដល់៖

1. ភាពស្និទ្ធស្នាលកាន់តែខ្លាំងរវាងប្តីប្រពន្ធ (លោកុប្បត្តិ ២:២៥)
2. ការបង្កើតកូនចៅ (លោកុប្បត្តិ ១:២៨)
3. ជាជំនួយយកឈ្នះលើសេចក្តីល្បួង (១ កូរិនថូស ៧:៣-៥)

ក្នុងអាពាហ៍ពិពាហ៍ ដែលប្តីនិងប្រពន្ធជាអ្នកកាន់តាមព្រះយេស៊ូវ ពួកគេតែងបើកចំហ ទាំងផ្លូវកាយ និងផ្លូវចិត្ត ចំពោះគ្នាទៅវិញទៅមក ដោយមិនមានលាក់បាំងអ្វីទាំងអស់។ នេះគឺជាអត្ថន័យរបស់ពាក្យ *«អាក្រាតទទេ ឥតមានសេចក្តីអៀនខ្មាសឡើយ»* (លោកុប្បត្តិ ២:២៥) ហើយនេះគឺជាអត្ថន័យពិតប្រាកដនៃការរួមដំណេក។

ខ. សេចក្តីស្រឡាញ់ដែលបង្កើតផលផ្លែ

ព្រះជាម្ចាស់បានបង្កើតសេចក្តីស្រឡាញ់នៅក្នុងអាពាហ៍ពិពាហ៍ ដើម្បីបង្កើតផលផ្លែ ពោលគឺជាការបង្កើតកូនចៅ (ម៉ាឡាគី ៣:១៥)។ កូនៗ គឺជាព្រះពរដ៏អស្ចារ្យ ដែលគូស្វាមីភរិយាគ្រីស្ទបរិស័ទគួរទទួលដោយចិត្តអរព្រះគុណចំពោះព្រះជាម្ចាស់ជានិច្ច (ទំនុកដំកើង ១២៧:៣)។

អ្នក និងប្តីប្រពន្ធរបស់អ្នកគួរអធិស្ឋាន ហើយស្វែងរកព្រះហឫទ័យរបស់ព្រះជាម្ចាស់ អំពីចំនួនកូន ដែលទ្រង់ចង់ឲ្យអ្នកមាន និងពេលណាដែលអ្នកត្រូវមានកូន។ ក្នុងការធ្វើដូច្នេះ អ្នកទាំងពីរអាចនឹងសម្រេចចិត្តប្រើវិធីពន្យារកំណើតក្នុងកំឡុងពេលមួយ។ អ្នកទាំងពីរគួរតែពិភាក្សារឿងនេះមុនពេលរៀបការ។

ការរម្លូតកូនមិនខុសច្បាប់ទេ ប៉ុន្តែស្ទើរតែគ្រប់ករណីទាំងអស់នៃការរម្លូតកូន គឺជាអំពើបាបដ៏ធ្ងន់ធ្ងរមួយ។ គ្រីស្ទបរិស័ទមិនត្រូវរម្លូតកូនឡើយ លុះត្រាតែការមានគភ៌ អាចប៉ះពាល់ដល់អាយុជីវិតរបស់ម្តាយ (ឧទាហរណ៍ ការមានផ្ទៃពោះក្រៅស្បូន)។

ពេលខ្លះ ប្តីប្រពន្ធមួយចំនួន មិនអាចមានលទ្ធភាពចិញ្ចឹមកូនបន្ថែមទៀតបាន ឬគ្រូពេទ្យប្រាប់ថាកូនក្នុងផ្ទៃរបស់ម្តាយមិនមានសុខភាពល្អ ឬមិនមានកាយសម្បទាគ្រប់គ្រាន់។ សូម្បីតែក្នុងករណីបែបនេះក៏ដោយ គូស្វាមីភរិយាមិនត្រូវធ្វើឃាតកូនខ្លួន ដោយការរំលូតកូនឡើយ (និក្ខមនំ ២០:១៣)។ ផ្ទុយទៅវិញ ពួកគេត្រូវតែទទួលយកទារកគ្រប់រូប ជាព្រះពរពីព្រះជាម្ចាស់ ហើយទុកចិត្តលើផែនការរបស់ទ្រង់ សម្រាប់ក្រុមគ្រួសាររបស់ពួកគេ។

វាជាការដែលគួរឲ្យសោកស្តាយ ដែលគូស្វាមីភរិយាមួយចំនួន មានបញ្ហាក្នុងការមានកូន។ នៅក្នុងព្រះគម្ពីរ មានសាច់រឿងជាច្រើនដូចនេះដែរ (ឧទាហរណ៍ លោកអ័ប្រាហាំ និងនាងសារ៉ា)។ ពេលខ្លះ ព្រះជាម្ចាស់ឆ្លើយតបនឹងការអធិស្ឋានរបស់ប្តីប្រពន្ធដែលគ្មានកូន ហើយប្រទានពរឲ្យពួកគេមានកូន។ ប៉ុន្តែពេលខ្លះទៀត យើងមិនដឹងថាមូលហេតុអ្វី បានជាព្រះជាម្ចាស់មិនបានឆ្លើយតប នឹងសេចក្តីអធិស្ឋាននោះឡើយ។ ប៉ុន្តែនៅក្នុងគ្រប់រឿងទាំងអស់ ព្រះជាម្ចាស់សន្យាថា ទ្រង់នឹងប្រើរឿងពិបាកទាំងអស់ ដើម្បីបង្កើតផលល្អ (រ៉ូម ៨:២៨)។

គ. ការរួមដំណេកឥតសៅហ្មង

ព្រះគម្ពីរចែងថា៖ *«សូមឲ្យមនុស្សទាំងអស់លើកតម្លៃអាពាហ៍ពិពាហ៍ ហើយសូមឲ្យការរួមដំណេកបានជាឥតសៅហ្មង ដ្បិតព្រះនឹងជំនុំជម្រះមនុស្សសហាយស្មន់ និងមនុស្សផិតក្បត់»* (ហេព្រើរ ១៣:៤)។

ការរួមភេទរវាងប្តីប្រពន្ធគឺល្អ និងបរិសុទ្ធ។ វាគឺជាការបញ្ជាក់ពីភាពស្និទ្ធស្នាលបំផុតនៃសេចក្តីស្រឡាញ់ និងការរួបរួមរបស់ប្តីប្រពន្ធ។ នោះហើយជាមូលហេតុដែលអំពើផិតក្បត់ គឺពិតជាអំពើអាក្រក់ខ្លាំងណាស់។ វាបង្កឲ្យមានការបាក់បែក និងការឈឺចាប់ដ៏ធ្ងន់ធ្ងរ ហើយវាក៏បំផ្លិចបំផ្លាញសេចក្តីស្រឡាញ់ និងការរួបរួមគ្នារវាងប្តីប្រពន្ធ។

វាជាការសំខាន់ខ្លាំងណាស់សម្រាប់អ្នក និងប្តីឬប្រពន្ធរបស់អ្នក ដើម្បីការពារគ្រែផ្សំដំណេកអាពាហ៍ពិពាហ៍របស់អ្នក ពីអ្វីៗដែលអាចធ្វើឲ្យវាសៅហ្មង។ នេះមានន័យថា អ្នកត្រូវតែព្យាយាមរក្សាភាពស្មោះត្រង់ចំពោះគ្នាទៅវិញទៅមក តាមគ្រប់មធ្យោបាយទាំងផ្លូវកាយ និងផ្លូវចិត្ត។ ដើម្បីធ្វើដូចនេះបាន អ្នកគួរ៖

- ចំណាយពេលតែម្នាក់ឯងជាមួយព្រះជាម្ចាស់ជារៀងរាល់ថ្ងៃ (បើអ្នកមានទំនាក់ទំនងជិតស្និទ្ធជាមួយព្រះជាម្ចាស់ ប្រាកដជាអ្នកនឹងមិនក្បត់ប្តីឬប្រពន្ធរបស់អ្នកទេ។)
- អធិស្ឋានជាមួយប្តី ឬប្រពន្ធរបស់អ្នកជាប្រចាំថ្ងៃ
- រីករាយនឹងការរួមដំណេកជាមួយគ្នាជាប្រចាំ
- កុំមើលរូបភាពមិនសមរម្យ ឬរឿងអាសអាភាស
- កុំចែចង់ ឬចំណាយពេលតែម្នាក់ឯងជាមួយមនុស្សភេទផ្ទុយគ្នា
- សារភាពអំពើបាប និងភាពទន់ខ្សោយរបស់អ្នកចំពោះគ្នាទៅវិញទៅមក
- ជួបជាមួយមិត្តភក្តិគ្រីស្ទបរិស័ទដែលមានភេទដូចគ្នា ដែលអ្នកអាចចែករំលែកដោយបើកចំហអំពីការល្បួងដែលអ្នកកំពុងប្រឈមមុខ ដើម្បីឲ្យគេលើកទឹកចិត្ត និងអធិស្ឋានសម្រាប់អ្នក

ឃ. ទម្លាប់សំខាន់៖ រៀនអំពីគ្នាទៅវិញទៅមក

ប្ដីប្រពន្ធមិនត្រូវប្រើប្រាស់គ្នាដើម្បីបំពេញចិត្តខ្លួនឡើយ។ ផ្ទុយទៅវិញ ក្នុងកិច្ចការគ្រប់យ៉ាង (រួមទាំងពេលរួមដំណេក) គោលបំណងរបស់ស្វាមីគួរតែធ្វើឲ្យភរិយាពេញចិត្ត ហើយគោលបំណងរបស់ភរិយាគួរតែធ្វើឲ្យស្វាមីពេញចិត្តជានិច្ច (១ កូរិនថូស ៧:៣៣-៣៤)។

ជាធម្មតា បើនិយាយទៅដល់ការរួមភេទ ការចង់បានរបស់ប្ដីនិងប្រពន្ធមិនតែងតែដូចគ្នានោះទេ។ ហេតុនេះហើយ ដើម្បីបំពេញចិត្តគ្នាទៅវិញទៅមកក្នុងផ្នែកនេះ វាជារឿងសំខាន់សម្រាប់ស្វាមីភរិយាក្នុងការសិក្សាស្វែងយល់ពីគ្នាទៅវិញទៅមក។

សម្រាប់បុរស ការរួមភេទ គឺសំដៅដល់រាងកាយជាជាងអារម្មណ៍។ ប្រដាប់ភេទរបស់បុរស ផលិតមេជីវិតឈ្មោលរាប់លានមេជីវិតជារៀងរាល់ថ្ងៃ។ ពេលដែលប្រដាប់ភេទរបស់បុរសកាន់តែរីកធំ នោះចំណង់ផ្លូវភេទរបស់គាត់ក៏កាន់តែខ្ពស់តាមនោះដែរ។ នេះមានន័យថា បុរសជាប្ដីភាគច្រើន មានអារម្មណ៍ចង់រួមភេទញឹកញាប់ជាងប្រពន្ធ។ វាក៏ជាហេតុផលដែលបុរសភាគច្រើនឆាប់ស្រើបស្រាល ឈានដល់ចំណុចកំពូលយ៉ាងងាយស្រួល និងបាត់បង់ចំណាប់អារម្មណ៍ក្នុងការរួមភេទភ្លាមៗ បន្ទាប់ពីចេញទឹកកាម។

សម្រាប់ស្ត្រីវិញ ការរួមភេទ គឺសំដៅដល់អារម្មណ៍ជាជាងរូបកាយ។ នេះមានន័យថា ដើម្បីឲ្យប្រពន្ធចង់ស្និទ្ធស្នាលជាមួយស្វាមីខាងផ្លូវកាយបាន នាងត្រូវតែមានអារម្មណ៍ស្និទ្ធស្នាលនឹងគាត់តាមផ្លូវអារម្មណ៍សិន។ លើសពីនេះទៅទៀត ខណៈពេលដែលបុរសផលិតមេជីវិតឈ្មោលរាប់លានមេជីវិតជារៀងរាល់ថ្ងៃ ស្ត្រីវិញផលិតត្រឹមតែពងជីវិតមួយក្នុងមួយខែប៉ុណ្ណោះ។ ជាលទ្ធផល ក្នុងករណីភាគច្រើន ប្រពន្ធមិនមានអារម្មណ៍ថាត្រូវរួមភេទញឹកញាប់ ដូចប្ដីរបស់ពួកគេនោះទេ។ លើសពីនេះទៅទៀត ស្ត្រីមានចំណង់ផ្លូវភេទយឺតជាងបុរស។ វាមិនមែនងាយស្រួលសម្រាប់ស្ត្រីក្នុងការទទួលបានអារម្មណ៍ដល់ចំណុចកំពូលដូចបុរសនោះទេ។ ហើយចំណង់ផ្លូវភេទរបស់ស្ត្រីក៏មិនរសាយបាត់ភ្លាមៗបន្ទាប់ពីដល់ចំណុចកំពូលដែរ។

នៅពេលអ្នករៀបការដំបូង សូមកុំបារម្ភ ប្រសិនបើការរួមភេទរវាងអ្នក និងប្ដីឬប្រពន្ធរបស់អ្នកមានភាពឆ្គាំឆ្គងបន្តិច។ គន្លឹះនៃការមានជីវិតផ្លូវភេទដ៏រីករាយគឺ ទីមួយត្រូវព្យាយាមផ្គាប់ចិត្តគ្នាទៅវិញទៅមក និងទីពីរគឺស្វែងយល់ពីគ្នាទៅវិញទៅមក។

ដើម្បីស្វែងយល់ពីគ្នាទៅវិញទៅមកបាន អ្នកទាំងពីរត្រូវតែហ៊ាននិយាយជាមួយគ្នាអំពីការរួមភេទ។ អ្នកគួរសួរប្ដីឬប្រពន្ធរបស់អ្នកនូវសំណួរដូចជា «តើអូនចូលចិត្តទេ ពេលបងធ្វើបែបនេះ?»។ ហើយប្រសិនបើមានអ្វីដែលអ្នកមិនសូវចូលចិត្ត អ្នកគួរតែឲ្យប្ដីប្រពន្ធរបស់អ្នកបានដឹង។ វាពិបាកសម្រាប់គូស្វាមីភរិយារបស់អ្នក ក្នុងការដឹងពីរបៀបធ្វើឲ្យអ្នកពេញចិត្តចំពោះការរួមដំណេក ប្រសិនបើអ្នកមិនហ៊ាននិយាយដោយបើកចំហជាមួយគ្នា។

ង. សំណួរពិភាក្សាជាមួយអ្នកប្រឹក្សា (បុរសជួបជាមួយបុរស និងស្ត្រីជួបជាមួយស្ត្រី)

1. តើអ្នកបានធ្វើកិច្ចការផ្ទះហើយ ឬនៅ? តើអ្នកគិតដូចម្តេច អំពីកិច្ចការផ្ទះនោះ?
2. តើចំណុចអ្វីខ្លះ ក្នុងមេរៀនដែលទាក់ទាញចំណាប់អារម្មណ៍អ្នក?
3. តើមានចំណុចអ្វីខ្លះ នៅក្នុងមេរៀននេះ ដែលអ្នកមិនទាន់យល់ទេ?
4. តាមការយល់ដឹងរបស់អ្នក តើការរួមភេទរវាងប្តីប្រពន្ធល្អ ឬអាក្រក់ ស្អាត ឬកខ្វក់?
5. តើការរួមភេទក្នុងអាពាហ៍ពិពាហ៍មានអត្ថប្រយោជន៍អ្វីខ្លះ?
6. តើអ្នកនិងប្តីប្រពន្ធរបស់អ្នក បាននិយាយអំពីការមានកូនទេ? តើអ្នកបាននិយាយអំពីការពន្យារកំណើតទេ?
7. តើអ្នកគិតយ៉ាងណាចំពោះការរំលូតកូន?
8. តើអ្នកនឹងធ្វើអ្វី ដើម្បីការពារភាពបរិសុទ្ធនៃគ្រែអាពាហ៍ពិពាហ៍របស់អ្នក?
9. តើអ្នកមានអារម្មណ៍យ៉ាងណាចំពោះការរួមភេទបន្ទាប់ពីអ្នករៀបការ? តើមានអ្វីដែលអ្នកព្រួយបារម្ភទេ?
10. បន្ទាប់ពីអ្នករៀបការហើយ ហេតុអ្វីបានជាវាសំខាន់ក្នុងការនិយាយជាមួយគូស្វាមីភរិយារបស់អ្នកអំពីការរួមភេទ និងពីចំណុចអ្វីដែលអ្នកចូលចិត្ត និងមិនចូលចិត្ត? តើអ្នកនឹងហ៊ាននិយាយជាមួយគ្នាពីរឿងនេះទេ?
11. តើមានចំណុចអ្វីផ្សេងទៀត ដែលអ្នកចង់សួរ ឬពិភាក្សាគ្នា នៅថ្ងៃនេះ ឬទេ?

ច. កិច្ចការផ្ទះ

1. សូមជួបជាមួយគូដណ្តឹងរបស់អ្នក ហើយសួរគ្នាទៅវិញទៅមកនូវសំណួរពិភាក្សាជាមួយដៃគូ ៤០-៤២ នៅក្នុងឧបសម្ព័ន្ធ។
2. សូមអធិស្ឋានជាមួយគ្នា យ៉ាងហោចណាស់ម្តងក្នុងមួយសប្តាហ៍។

ឧបសម្ព័ន្ធ

«តើខ្ញុំគួររៀបការជាមួយមនុស្សនេះទេ ?»

១	តើគាត់ស្រឡាញ់ ទុកចិត្ត និងស្តាប់បង្គាប់ព្រះយេស៊ូវឬទេ ?	មែន / មិនប្រាកដ / ទេ
២	តើគាត់ពិតជាស្រឡាញ់ គោរព និងឲ្យតម្លៃខ្ញុំមែនទេ ?	មែន / មិនប្រាកដ / ទេ
៣	តើគាត់ចង់គ្រប់គ្រង ឬផ្លាស់ប្តូរខ្ញុំទេ ?	មែន / មិនប្រាកដ / ទេ
៤	តើគាត់ស្មោះត្រង់នឹងរឿងតូចឬធំទេ ?	មែន / មិនប្រាកដ / ទេ
៥	តើគាត់ស្រឡាញ់ និងគោរពឪពុកម្តាយរបស់គាត់ទេ ?	មែន / មិនប្រាកដ / ទេ
៦	តើគាត់នឹងស្រឡាញ់ និងគោរពឪពុកម្តាយរបស់ខ្ញុំទេ ?	មែន / មិនប្រាកដ / ទេ
៧	តើគាត់ចេះទទួលខុសត្រូវឬទេ ?	មែន / មិនប្រាកដ / ទេ
៨	តើគាត់គឺជាមនុស្សម្នាក់ដែលគួរឲ្យគោរពឬទេ ?	មែន / មិនប្រាកដ / ទេ
៩	តើខ្ញុំចាប់អារម្មណ៍គាត់ទេ ទាំងរូបរាងកាយ និងចិត្តគំនិតរបស់គាត់ ?	មែន / មិនប្រាកដ / ទេ
១០	តើខ្ញុំមានអារម្មណ៍ថាមានសុវត្ថិភាពក្នុងការចែករំលែកអារម្មណ៍ពិតរបស់ខ្ញុំ (មិនថាល្អ ឬអាក្រក់) ជាមួយគាត់ឬទេ ?	មែន / មិនប្រាកដ / ទេ
១១	តើខ្ញុំជាអាទិភាពក្នុងជីវិតរបស់គាត់ឬទេ ?	មែន / មិនប្រាកដ / ទេ
១២	តើគាត់មានទម្លាប់ណាដែលអាចប៉ះពាល់ដល់សុខភាពគាត់ ឬគ្រួសារយើងដែរឬទេ (ដូចជាជក់បារី) ?	មែន / មិនប្រាកដ / ទេ
១៣	តើគាត់ចេះសុំទោសអ្នកដទៃ នៅពេលដែលគាត់ធ្វើខុសដែរឬទេ ?	មែន / មិនប្រាកដ / ទេ
១៤	តើគាត់រក្សាគំនុំក្នុងចិត្តគាត់ដែរឬទេ ?	មែន / មិនប្រាកដ / ទេ
១៥	តើយើងឈ្លោះគ្នាញឹកញាប់ទេ ?	មែន / មិនប្រាកដ / ទេ
១៦	ក្នុងរយៈពេល ២០ឆ្នាំខាងមុខ ប្រសិនបើចរិតរបស់គាត់នៅតែដូចឥឡូវនេះ តើខ្ញុំនៅតែសប្បាយចិត្តឬទេ ?	មែន / មិនប្រាកដ / ទេ
១៧	តើខ្ញុំនឹងមានមោទនភាពក្នុងការហៅគាត់ថាប្តី/ប្រពន្ធរបស់ខ្ញុំ និងជាឪពុក/ម្តាយរបស់កូនរបស់ខ្ញុំដែរឬទេ ?	មែន / មិនប្រាកដ / ទេ

១៨	ប្រសិនបើខ្ញុំធ្លាក់ខ្លួនឈឺ ឬពិការ តើខ្ញុំអាចទុកចិត្តគាត់ឲ្យមើលថែទាំខ្ញុំបានទេ ?	មែន / មិនប្រាកដ / ទេ
១៩	ប្រសិនបើខ្ញុំស្លាប់មុនអាយុ តើខ្ញុំអាចទុកចិត្តគាត់ឲ្យមើលថែកូនរបស់យើង ហើយចិញ្ចឹមពួកគេក្នុងព្រះអម្ចាស់បានទេ ?	មែន / មិនប្រាកដ / ទេ
២០	តើយើងមានគោលដៅជីវិតដូចគ្នាទេ ?	មែន / មិនប្រាកដ / ទេ

សំណួរពិភាក្សាជាមួយដៃគូ

ប្រវត្តិជីវិត

១. តើកុមារភាពរបស់អ្នកមានលក្ខណៈបែបណា?
២. កាលនៅវ័យជំទង់ តើអ្នកចូលចិត្តអ្វី?
៣. មុនយើងបានស្គាល់គ្នា តើថ្ងៃណា ជាថ្ងៃល្អបំផុតក្នុងជីវិតរបស់អ្នក? តើថ្ងៃណាដែលអាក្រក់បំផុត?
៤. តើអ្នកធ្លាប់មានស្នេហាជាមួយអ្នកផ្សេងទេ? បើដូច្នេះ តើអ្នកនៅមានអារម្មណ៍បែបណាសម្រាប់គេ?
៥. តើអ្នកធ្លាប់ស្និទ្ធស្នាលផ្នែករូបរាងកាយ នឹងមនុស្សណាម្នាក់ដែរឬទេ?
៦. តើមានព្រឹត្តិការណ៍សំខាន់ៗ ឬឈឺចាប់ក្នុងអតីតកាលដែលអ្នកមិនទាន់ប្រាប់ខ្ញុំទេ?

ជំនឿ

៧. តើព្រះយេស៊ូវជានរណាសម្រាប់អ្នក?
៨. តើវាសំខាន់សម្រាប់អ្នក ក្នុងការរៀបការបែបគ្រីស្ទបរិស័ទឬទេ? ហេតុអ្វី?
៩. សម្រាប់អ្នក តើវាសំខាន់ទេដែលយើងរស់នៅជាមួយគ្នាជាគ្រួសារដែលដើរតាមព្រះយេស៊ូវ? តើនេះមានន័យយ៉ាងណាចំពោះអ្នក?

អនាគត

១០. បន្ទាប់ពីយើងរៀបការ តើយើងទៅរស់នៅឯណា?
១១. បន្ទាប់ពីយើងរៀបការ តើយើងនឹងផ្គត់ផ្គង់គ្រួសារថ្មីយើងតាមរបៀបណា?
១២. តើអ្នកមានគោលដៅជីវិតអ្វីខ្លះ?

អាពាហ៍ពិពាហ៍

១៣. ហេតុអ្វីបានជាអ្នកចង់រៀបការជាមួយខ្ញុំ?
១៤. តើអាពាហ៍ពិពាហ៍មានន័យយ៉ាងណាចំពោះអ្នក?
១៥. តើអ្នកស្រឡាញ់ខ្ញុំ ត្រង់ចំណុចណាខ្លះ? (រៀបរាប់យ៉ាងតិចឲ្យបាន៣ចំណុច)

ចរិតលក្ខណៈ

១៦. តើអ្វីខ្លះ ជាចំណុចខ្លាំងរបស់អ្នក? (រៀបរាប់យ៉ាងតិចឲ្យបាន៣ចំណុច)
១៧. តើចំណុចខ្សោយផ្ទាល់ខ្លួន របស់អ្នកមានអ្វីខ្លះ? (រៀបរាប់យ៉ាងតិចឲ្យបាន៣ចំណុច)
១៨. តើយើងស្រដៀងគ្នា ត្រង់ចំណុចណាខ្លះ? តើយើងខុសគ្នា ត្រង់ចំណុចណាខ្លះ?

សុខភាព

១៩. តើអ្នកមានជំងឺរ៉ាំរ៉ៃ ឬជំងឺអ្វីដែរឬទេ?
២០. តើអ្នកមានលេបថ្នាំប្រចាំដែរឬទេ? បើមាន តើជាថ្នាំសម្រាប់ជម្ងឺអ្វីខ្លះ?
២១. មុនយើងរៀបការ តើអ្នកយល់ព្រមទៅជួបគ្រូពេទ្យដើម្បីពិនិត្យសុខភាពឬទេ?

សេចក្តីស្រឡាញ់

២២. តើចំណុចណាខ្លះ ដែលធ្វើឲ្យអ្នកមានអារម្មណ៍ជិតស្និទ្ធនឹងខ្ញុំ?

២៣. តើចំណុចណាខ្លះ ដែលធ្វើឲ្យអ្នកមានអារម្មណ៍ថាឆ្ងាយពីខ្ញុំ?

២៤. តើអ្នកចង់ឲ្យខ្ញុំធ្វើអ្វី (ឬមិនធ្វើអ្វី) ដើម្បីបង្ហាញការស្រឡាញ់ និងការគោរពចំពោះអ្នក?

ជីវិតរួមគ្នា

២៥. ក្នុងគំនិតរបស់អ្នក តើប្តីល្អធ្វើអ្វីខ្លះ?

២៦. ក្នុងគំនិតរបស់អ្នក តើប្រពន្ធល្អធ្វើអ្វីខ្លះ?

២៧. បើនិយាយពីការងារផ្ទះវិញ តើអ្នកមិនចូលចិត្ត (ឬមិនចេះ) ធ្វើអ្វីខ្លះ?

គ្រួសារ

២៨. បន្ទាប់ពីយើងរៀបការហើយ តើអ្នករំពឹងថាទំនាក់ទំនងរបស់ខ្ញុំ ជាមួយគ្រួសារអ្នកនឹងទៅជាយ៉ាងណា?

២៩. បន្ទាប់ពីយើងរៀបការហើយ តើអ្នករំពឹងថាទំនាក់ទំនងរបស់អ្នកជាមួយគ្រួសារខ្ញុំ នឹងទៅជាយ៉ាងណា?

៣០. នៅពេលអនាគត ប្រសិនបើខ្ញុំមានបញ្ហាជាមួយនរណាម្នាក់ក្នុងគ្រួសាររបស់អ្នក តើអ្នកនឹងណែនាំឲ្យពួកយើងទាំងពីរធ្វើអ្វី?

មិត្តភក្តិ

៣១. ក្រៅពីខ្ញុំ តើអ្នកណាខ្លះ ជាមិត្តជិតស្និទ្ធបំផុតរបស់អ្នក? (ប្រាប់ឈ្មោះឲ្យបាន៣នាក់)

៣២. បន្ទាប់ពីយើងរៀបការហើយ តើអ្នករំពឹងថាទំនាក់ទំនងរបស់អ្នក និងមិត្តភក្តិរបស់អ្នកនឹងមានលក្ខណៈបែបណា?

៣៣. បន្ទាប់ពីយើងរៀបការហើយ តើអ្នកនឹងទាក់ទងមិត្តភក្តិភេទផ្ទុយគ្នា ក្នុងរូបភាពបែបណា?

ហិរញ្ញវត្ថុ

៣៤. តើអ្នកមានជំពាក់បំណុលទេ?

៣៥. បន្ទាប់ពីយើងរៀបការហើយ តើយើងនឹងចាត់ចែងលុយដោយរបៀបណា?

៣៦. បន្ទាប់ពីយើងរៀបការហើយ បើសមាជិកគ្រួសារអ្នកសុំខ្ចីលុយ តើអ្នកនឹងធ្វើយ៉ាងណា?

ទំនាស់

៣៧. ពេលអ្នកខឹងនឹងនរណាម្នាក់ តើអ្នកប្រព្រឹត្តយ៉ាងណា?

៣៨. បើអ្នកធ្វើឲ្យនរណាម្នាក់ឈឺចាប់ តើអ្នកនឹងសុំទោសគេដែរឬទេ?

៣៩. បើមានអ្នកណាធ្វើឲ្យអ្នកឈឺចាប់ តើអ្នកត្រូវការពេលយូរប៉ុណ្ណា ទម្រាំអ្នកអាចអត់ទោសឲ្យគេបាន?

កូន

៤០. តើអ្នកចង់មានកូនទេ? បើចង់ តើចង់បាននៅពេលណា? បើមិនចង់បានកូនទេ ហេតុអ្វី?

៤១. តើអ្នកគិតយ៉ាងណា ចំពោះការរំលូតកូន?

៤២. បើខ្ញុំមិនអាចមានកូនដោយមូលហេតុណាមួយ តើអ្នកនឹងធ្វើអ្វី?

តើព្រះគម្ពីរចែងអ្វីខ្លះអំពីការលែងលះ ?

ព្រះគម្ពីរ៖ ម៉ាឡាគី ២:១៥-១៦, ម៉ាថាយ ៥:៣១-៣២, ម៉ាថាយ ១៩:៣-៩, ម៉ាកុស ១០:២-១០, លូកា ១៦:១៨, រ៉ូម ៧:២-៣, ១ កូរិនថូស ៧:១០-១៦, ១ កូរិនថូស ៧:៣៩

អ្វីដែលព្រះគម្ពីរបង្រៀនអំពីការលែងលះ អាចត្រូវបានសង្ខេបជាប្រាំចំណុច៖

១. ***រូបកាយតែមួយ៖*** នៅពេលដែលបុរស និងស្ត្រីរៀបការ ព្រះជាម្ចាស់ធ្វើឲ្យពួកគេរួបរួមគ្នាជារូបកាយតែមួយ។ ចំណងអាពាហ៍ពិពាហ៍មិនមែនគ្រាន់តែជាកិច្ចសន្យារបស់មនុស្សប៉ុណ្ណោះទេ ប៉ុន្តែវាក៏គឺជាសម្ព័ន្ធមេត្រីរបស់ព្រះជាម្ចាស់ផងដែរ។

២. **ពេញមួយជីវិត៖** ដោយសារព្រះជាម្ចាស់ជាអ្នកបង្រួបបង្រួមពួកគេជារូបកាយតែមួយ មានតែទ្រង់ប៉ុណ្ណោះដែលមានសិទ្ធិបំបែកអាពាហ៍ពិពាហ៍ដោយការស្លាប់របស់ភាគីម្ខាង ឬសងខាង។

៣. **មិនអាចបំបែកបាន៖** ព្រះជាម្ចាស់មិនអនុញ្ញាតឲ្យប្ដីប្រពន្ធគ្រីស្ទបរិស័ទលែងលះគ្នាទេ។ លើសពីនេះទៅទៀត បើប្ដីប្រពន្ធលែងលះគ្នា ក៏ពួកគេនៅតែជារូបកាយតែមួយក្នុងព្រះនេត្ររបស់ព្រះជាម្ចាស់ដដែល។ លិខិតលែងលះរបស់មនុស្សមិនមានន័យអ្វី ចំពោះព្រះជាម្ចាស់នោះទេ។ ហេតុនេះហើយបានជាប្រសិនបើមនុស្សម្នាក់លែងលះប្ដីប្រពន្ធទៅរៀបការជាម្នាក់ផ្សេងទៀត នោះព្រះជាម្ចាស់មិនទទួលស្គាល់អាពាហ៍ពិពាហ៍លើកទីពីរនោះទេ។ ចំពោះព្រះអង្គ អាពាហ៍ពិពាហ៍លើកទីពីរ គឺជាអំពើផិតក្បត់។

៤. **ការនៅបែកគ្នា៖** ប្រសិនបើប្ដីប្រពន្ធដែលមិនមែនជាគ្រីស្ទបរិស័ទ មិនព្រមរស់នៅជាមួយប្ដី/ប្រពន្ធជាគ្រីស្ទបរិស័ទ នោះប្ដីប្រពន្ធដែលមិនមែនជាគ្រីស្ទបរិស័ទមានសេរីភាពក្នុងការចាកចេញ។ នៅក្នុងកាលៈទេសៈមួយចំនួន (ឧទាហរណ៍ រឿងអំពើហិង្សា) ប្ដី/ប្រពន្ធដែលជាគ្រីស្ទបរិស័ទ អាចបែកពីប្ដី/ប្រពន្ធរបស់ខ្លួនមួយរយៈបាន ដើម្បីការពារកូនៗ និងការពារខ្លួនឯង។ ទោះយ៉ាងណាក៏ដោយ នេះមិនមានន័យថា ពួកគេអាចលែងលះ និងរៀបការជាមួយអ្នកផ្សេងបានទេ។ ទោះបីជាពួកគេមិនបានរស់នៅជាមួយគ្នាក៏ដោយ ប៉ុន្តែចំពោះព្រះជាម្ចាស់វិញ ពួកគេនៅតែជារូបកាយតែមួយដដែល។

៥. **ករណីលើកលែងមួយ៖** ព្រះជាម្ចាស់មិនអនុញ្ញាតឲ្យមនុស្សលែងលះប្ដីប្រពន្ធ ហើយរៀបការជាមួយមនុស្សថ្មីនោះទេ លើកលែងតែក្នុងករណីតែមួយគត់ គឺការផិតក្បត់ (ម៉ាថាយ ១៩:៩)។ ប្រសិនបើបុគ្គលមានប្ដីឬប្រពន្ធដែលប្រព្រឹត្តអំពើផិតក្បត់ នោះព្រះយេស៊ូវ អនុញ្ញាតឲ្យបុគ្គលនោះ លែងលះប្ដីប្រពន្ធដែលមិនស្មោះត្រង់របស់ខ្លួន និងរៀបការជាមួយអ្នកផ្សេងទៀតបាន។ ការលែងលះប្ដី ឬប្រពន្ធដែលមិនស្មោះត្រង់ជាមួយយើង មិនមែនជាសេចក្ដីបង្គាប់របស់ព្រះយេស៊ូវ ដល់គ្រីស្ទបរិស័ទនោះទេ តែបើការណ៍នោះកើតមានមែន ទ្រង់នឹងផ្ដល់សេរីភាពដល់យើង ក្នុងការសម្រេចចិត្តថាត្រូវបន្តរស់នៅជាមួយគ្នាទៀត ឬក៏ត្រូវលែងលះគ្នា។

ការពន្យល់បន្ថែមអំពី អេភេសូរ ៥:២២-២៤

១. «ប្ដីជាក្បាលរបស់ប្រពន្ធ» (អេភេសូរ ៥:២៣)

ក. នេះ**មិនមែន**មានន័យថាៈ	ខ. នេះមានន័យថាៈ
• ប្ដីសំខាន់ជាងប្រពន្ធ • ប្ដីមានតម្លៃជាងប្រពន្ធ • ប្ដីឆ្លាតជាងប្រពន្ធ • ប្ដីមានសិទ្ធិគ្រប់គ្រងប្រពន្ធ • ប្ដីមានសិទ្ធិធ្វើបាបប្រពន្ធ	• ប្ដីត្រូវគិតគូរពីប្រពន្ធ • ប្ដីត្រូវតែបម្រើប្រពន្ធរបស់ខ្លួន • ប្ដីត្រូវមើលថែទាំប្រពន្ធ • ប្ដីត្រូវតែការពារប្រពន្ធរបស់ខ្លួន • ប្ដីត្រូវដឹកនាំប្រពន្ធរបស់ខ្លួន តាមផ្លូវរបស់ព្រះជាម្ចាស់ • ប្ដីត្រូវចាត់ទុកប្រពន្ធថាសំខាន់ជាងខ្លួន

២. «បងប្អូនជាស្ត្រីដែលមានស្វាមី ត្រូវគោរពចុះចូលនឹងស្វាមីរៀងៗខ្លួន» (អេភេសូរ ៥:២២)

ក. នេះ**មិនមែន**មានន័យថាៈ	ខ. នេះមានន័យថាៈ
• ប្រពន្ធត្រូវតែយល់ស្របជាមួយប្ដីជានិច្ច • ប្រពន្ធមិនត្រូវចែកចាយគំនិតរបស់ខ្លួនជាមួយប្ដី • ប្រពន្ធត្រូវធ្វើគ្រប់កិច្ចការទាំងអស់តាមប្ដី • ប្រពន្ធត្រូវតែអត់អោនចំពោះការរំលោភបំពាន ឬអំពើហិង្សានានា • ប្រពន្ធគឺជាទាសកររបស់ប្ដី	• ប្រពន្ធត្រូវគោរពប្ដី • ប្រពន្ធត្រូវតែឲ្យតម្លៃប្ដី • ប្រពន្ធត្រូវតែលើកទឹកចិត្តប្ដី • ប្រពន្ធត្រូវតែជួយប្ដី • ប្រពន្ធត្រូវធ្វើតាមប្ដី ក្នុងការដើរតាមផ្លូវរបស់ព្រះជាម្ចាស់ • ប្រពន្ធត្រូវចាត់ទុកប្ដីថាសំខាន់ជាងខ្លួន

តារាងរៀបចំកញ្ចប់ថវិកាប្រចាំគ្រួសារ

តារាងនេះ គឺជាមធ្យោបាយដ៏សាមញ្ញមួយ ក្នុងការជួយឲ្យគ្រួសាររបស់អ្នកអាចគ្រប់គ្រងកញ្ចប់ថវិកាបាន។

ចំណូល

ក្នុងមួយខែៗ តើគ្រួសាររបស់អ្នករកចំណូលបានប៉ុន្មាន?	៛

ចំណាយ

ថ្វាយព្រះ (ដង្វាយមួយភាគដប់)	៛
ផ្ទះ (បង់រំលោះ ឬជួលផ្ទះ)	៛
វិក្កយបត្រ (ទឹក ភ្លើង ថ្លៃប្រមូលសំរាម កាតទូរស័ព្ទ)	៛
យានជំនិះ (បង់រំលោះ សាំង ជួសជុលពេលខូច)	៛
អាហារ (តម្លៃសរុបប្រចាំខែ)	៛
ការជួយឪពុកម្ដាយ	៛
កូនៗ (កន្ទបទារក ថ្នាំសង្កូវ ថ្លៃបង់សាលា)	៛
ចំណាយចាំបាច់ផ្សេងទៀត	៛
សរុប	**៛**

ប្រាក់នៅសល់

ចំណូលសរុប________៛ ដក (-) ចំណាយសរុប________៛ = ប្រាក់នៅសល់សរុប _________៛

ប្រាក់នៅសល់សរុប	៛
ប្រាក់សន្សំ	៛
ចំណាយនានា (មិនចាំបាច់)	៛
ផ្សេងៗ	៛